ការសម្ភាសន៍របស់លោកពូ ពោជ ចាន់ថា

កៈ អ្នកសម្ភាសន៍អាង ប៊ុនសាយ័ន្ត ខៈ អ្នកត្រូវបានគេសម្ភាសន៍ ពោជ ចាន់ថា

កៈ អញ្ចឹងជាដំបូងក៏សូមថ្លែងអំណរគុណទៅដល់លោកពូ ដែលបានផ្តល់ឱកាស និង ពេល
វេលាដើម្បីឱ្យខ្ញុំអាចមកជួបនឹងធ្វើការសម្ភាសន៍ទាក់ទងពីជីវប្រវត្តិនឹងដំណើររឿងទាំងឡាយ
ដែលកើតឡើងនៅក្នុងជីវិតរបស់គាត់សម្រាប់ទុក្ខដល់កូនចៅជំនាន់ក្រោយ
ដើម្បីគាត់អាច ស្លាប់ និង ឮពីបទពិសោធន៍ផ្សេងៗដែលលោកពូមាន។
ហើយការសម្ភាសនេះធ្វើឡើងនៅ ទីតាំងឈ្មោះភូមិ៣ សង្កាត់ចាក់អង្រែ
ក្រោមខណ្ឌមានជ័យ ក្រុងភ្នំពេញ។ ហើយអ្នកធ្វើកា សម្ភាសគឺខ្ញុំ អាង ប៊ុនសាយ័ន្ត
ហើយដែលការសម្ភាសនេះគឺធ្វើឡើងនៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ ២០១៧។
អញ្ចឹងខ្ញុំនឹងចាប់ផ្តើមការសម្ភាសន៍ជាមួយនឹងលោកពូតែម្តង
តើពូអាចប្រាប់ឈ្មោះ ពេញរបស់ពូបានទេ?

ខៈ បាន! ខ្ញុំឈ្មោះ ពោជ ចាន់ថា។

កៈ ពូមានឈ្មោះហៅក្រៅឬក៏គេហៅកាលពីនៅក្មេងអីផ្សេងទេ?

ខៈ អត់មានផង។

កៈ អត់មានទេ មានតែឈ្មោះហ្នឹងមួយទេហ្អ?

ខៈ ជាំទៗ!

កៈ ហើយសព្វថ្ងៃពូមានអាយុប៉ុន្មានឆ្នាំហើយ?

ខៈ ខ្ញុំអាយុ៥៣ឆ្នាំហើយ។

កៈ ៥៣ឆ្នាំ? ពូកើតឆ្នាំណាខែណាថ្ងៃណាដែរ?

ខៈ ឆ្នាំ១៩៦៤។

កៈ ចា! ពូកើតនៅថ្ងៃ?

ខៈ ទី១៥ ខែវិច្ឆិការ ឆ្នាំ១៩៦៤។

កៈ ចា! អញ្ចឹងពូទើបតែគ្រប់៥០...៥០ប៉ុន្មានមិញ៥៤ហ៎?

ខៈ ៥៣!

កៈ ៥៣ឆ្នាំ។

ខៈ ជាំទ!

កៈ ហើយទីកន្លែងកំណើតរបស់ពូនៅទីណាដែរ?

ខៈ នៅភូមិខ្ជាយ ឃុំរវាងកោរ ស្រុករំដួល ខេត្តស្វាយរៀង។

កៈ ចា! ពូចាំ..ដែលគេហៅថាឆ្នាំច័ន្ទគតិ ឬក៏ឆ្នាំសត្វរបស់ពូទេ?

ខៈ ឆ្នាំខ្ចីរហ្នឹងខ្ញុំអត់ចាំទេ។

កៈ អត់ដឹងទេហ្អ?

ខៈ ជាំទ! អត់ដឹង។

កៈ ចា! ពូហើយពូរស់នៅចាក់អង្រែក្រោមនេះអស់រយៈពេលប៉ុន្មានឆ្នាំហើយពូ?

ខៈ តាំងពីឆ្នាំ១៩៧៩មក ពេលខ្ញុំដំលៀសមកពីចាត់ដំបង ខ្ញុំទៅនៅស្រុកទៅដល់ស្រុក ពេលទៅធ្វើស្រូវធ្វើអត់បាន។

កៈ ចា!

ខៈ ដោយសារកណ្តុររាកាត់ហាស។

កៈ កាត់ស្រូវ?

ខៈ ធ្វើបានក៏ប៉ុន្តែកណ្តុររាកាត់អស់ហួងមួយហិចតា។

កៈ ចុម! កណ្តុរប៉ុន្មានគ្នាប៉ុន្មាននាក់នាំគ្នាកាត់អស់រលីង?

ខៈ ហើយចុះបើភូមិដែលគេបោះបង់ចោលយូរហ៎។

កៈ ចា! សំបូរសត្វ។

ខៈ ហ្នឹងហើយវា...ក្នុងជំនាន់ប៉ុលពតហ្នឹង
យើងបោះបង់ភូមិចោលទាំងស្រុងហើយហ្នឹង។

កៈ នៅណា?

ខៈ នៅស្វាយរៀងដល់អញ្ចឹងពេលទៅឃើញស្មៅលិចត្រឹមក្បាលយើងហ្អ៎។

កៈ ចា!

ខៈ ហើយនៅតាមនេះ...សុទ្ធតែគ្រាប់មីនទៀត។
ហ្នឹងហើយអ្នកខ្លះក៏ស្លាប់ដោយសារគ្រាប់ មីននៅក្នុងហ្នឹង
ព្រោះយើងចេះតែរុករកកណ្តុរនៅក្នុងហ្នឹងអីចឹងហ៎។

កះ ចាំ!
ខះ អញ្ចឹងបានជាខ្ញុំឆ្នាំ៨០ (១៩៨០)
ខ្ញុំវិលត្រឡប់មកវិញឱ្យបងប្រុសមកធ្វើការនៅរោង ចក្រនេះ។
កះ ធ្វើការរោងចក្រអីគេ?
ខះ រោងចក្រម្ជងនៀក តែពេលហ្នឹងអត់ទាន់ដំណើរការទេ
ក្រាន់តែឱ្យរៀបចំបោសសម្អាតអីចឹងទៅ។
កះ ចាំ!
ខះ ឆ្នាំ៨១(១៩៨១) ៨២(១៩៨២) គេចាប់ផ្តើមដំណើរការហើយគេក្បាញ្ចមោងអួន
ហើយ បានខ្ញុំមកតាមក្រោយគាត់ចូលមកធ្វើការនៅហ្នឹង។
កះ ចាំ!
ខះ ចូលមកធ្វើការហ្នឹងអត់ទាន់គ្រប់អាយុទៀតណា។
កះ អាយុប៉ុន្មានឆ្នាំ?
ខះ អាយុប្រហែលជា១៦ ១៧ឆ្នាំអីទេមើលទៅ។
កះ អញ្ចឹង!
ខះ ដល់តែពេលធ្វើការទៅអាហ្នឹងអត់បានរៀនសូត្រទៀត
តែអាយុយើងត្រូវបានចូលរៀន តែយើងអត់បានរៀនសូត្រ។
កះ ហ្នឹងអារដែងមកធ្វើការ?
ខះ អារដែងតែដោយសារជីវភាពយើងវាខ្វះខាតអញ្ចឹងហ៎ា
ហើយឪពុកម្តាយគាត់ចាស់ គាត់ ធ្វើការអត់កើត។
កះ ចាំ!
ខះ គាត់ឱ្យខ្ញុំចូលធ្វើការ។
កះ តាំងពីតូចមកមិនទាន់គ្រប់អាយុផង។
ខះ ចាំទ!
កះ អញ្ចឹងពូជាអ្នកស្រុកស្វាយរៀងទេ?
ខះ ចាំទ! នៅស្វាយរៀង។
កះ ហើយសម្រេចចិត្តមកនៅភ្នំពេញនេះដោយសារតែមកធ្វើការជាមួយនឹងបង?
ខះ ចាំទ! បងគាត់ស្គាល់...គាត់មានបងអី! បងប្រុសគាត់ម្នាក់ទៀត។
គាត់ជាប្រធានរោង ចក្រហ្នឹងហ៎ា។
គាត់រត់ទៅរៀតណាមដល់តែពេលគាត់មកវិញទៅ គេឱ្យគាត់កាន់កាប់នៅ
រោងចក្រហ្នឹង។
កះ ចាំ!
ខះ ដល់អញ្ចឹងស្គាល់ហើយឮដំណឹងអីចឹង ទៅក៏គាត់ចេះតែមកទៅណា ដល់អញ្ចឹង
គាត់ ផ្តល់ដំណឹងថាគាត់បានចូលធ្វើការអញ្ចឹង។
កាលហ្នឹងមិនទាន់មានប្រាក់ខែទេ ពេលធ្វើការ គេបើករបបជាអង្ករជាពោត
ជាពោតសាលីជាម្សៅមីមានគ្រប់បែបយ៉ាងអីចឹង។
កះ សម័យហ្នឹងគេអត់ទាន់ចាយលុយណាពូ?
ខះ នៅទេ តែគេចាយគឺចាយលុយរៀតណាម។
កះ អឺម!
ខះ ហ្នឹងមានលុយរៀតណាម។
កះ ចាំ!
ខះ លុយរៀតណាមហើយយើងចាយមាសយើងចាយអីចឹងទៅ ហ្នឹងហើយ ឧបមាថា
យើងទិញគោទិញក្របីអីទៅយើងយកមាសយើងយកលុយដុង
(កាលហ្នឹងគេចាយលុយ ដុង)។
កះ ហ្នឹងហើយសម័យមុនគេចាយមាសនឹងទ្រព្យសម្បត្តិនោះប្រើនណាស់។
ខះ ចាំទ!
កះ កប់...អ្នកខ្លះកប់ទុក្ខហើយអ្នកខ្លះយកតាមខ្លួន។
ខះ ចាំទ!
កះ ហើយកាលសម័យម៉ាក់ខ្ញុំនេះគាត់ប្រាប់ដែរតើ
ថាគេដូរយកមាសដូរយកអីចឹងហ៎ា មិន ទាន់ចាយលុយដូយើងឥឡូវ។
ខះ ចាំទ! កាលឆ្នាំៗមិនដឹងប៉ុន្មានទេ ដូចជាឆ្នាំ៨០ជាងអី?
គេចាប់ផ្តើមគេចាយលុយ
កាលហ្នឹងគេចាយកាក់ហើយកាលហ្នឹងប្រាក់ខែបានតែ៩០រទេ។
កះ ៩០រ?

ខ៖ ៩០៛លុយខ្មែរយើងហ្នឹងៗគេកាត់អង្ករអស់ហើយ។
ក៖ អត់ទាន់បានដល់១០០៛លុយខ្មែរទេ?
ខ៖ អត់ទាន់ដល់ទេ តែការពិតលុយវាដល់ហើយក៏ប៉ុន្តែគេកាត់ថ្លៃអង្ករថ្លៃរបប
អីផ្សេងៗទៅ ណ៎ា។
កាលហ្នឹងគេមានរបបមានទឹកដោះគោមានប្រេងកាតមានអី! សាប៊ូអីចឹងទៅ
អាហ្នឹង គេកាត់អស់ទៅនៅសល់តែ៩០៛ជាងទេ។
ក៖ ចា!
ខ៖ នៅសល់៩៩៛។
ក៖ ១០០៛លុយខ្មែរយើងនៅឥឡូវនេះគ្មានចាយស្អីបានផង
ហើយនៅក្នុងជំនាន់នោះ៩០៛ ចាយបានច្រើនហា។
ខ៖ ចាយបានច្រើនណាស់ ខោបើយើងចង់កាត់ខោមួយអស់តែប៉ុន្មាន?
អស់តែ៣០៛ហ្នឹង។
ក៖ អឺម! ម្យ៉ាងទៅ។
ខ៖ ប៉ាទ!
តែវាអត់បានយូរដែរហ្នឹងប្រហែលជាមួយឆ្នាំពីរឆ្នាំលុយចាប់ផ្តើមធ្លាក់ម្តង។
ក៖ ចា!
ខ៖ អាយុលុយកាក់លុយសេនអីហ្នឹង គេលែងចាយអស់ហើយ
គេផ្លាស់ប្តូរច្រើនហ្អង។
ក៖ ហ្នឹងហើយ ពូកាលសម័យម៉ាក់ប៉ាខ្ញុំគាត់នេះហ៎ា
គាត់ប្រាប់ថាគេចាយលុយកាក់ដល់
ពេលខ្ញុំធំឡើងមកគេឈប់ចាយលុយកាក់លុយអីហ្នឹងអស់ហើយ។
ខ៖ អាកាក់ហ្នឹងដូចគេមកឱ្យឃើញតែមួយភ្លែតហ្នឹង
មួយភ្លែតអញ្ចឹងទៅស្រាប់តែបាត់អស់ហ្អង។
គេលែងយកទៅចាយគេលែងចាយអស់ហើយ ដូចមកគ្រាន់តែបង្គ្រប់កិច្ចយ៉ាង
ម៉េចមិនដឹង។
ក៖ ហើយអឺ!សម្រាប់ពូបងប្អូនពូមានប៉ុន្មាននាក់ដែរ?
ខ៖ បងប្អូនមាន៥នាក់។
ក៖ ពូកូនទីប៉ុន្មាន?
ខ៖ ខ្ញុំកូនទី៣។
ក៖ ពូអាចរៀបរាប់ឈ្មោះពីបងមកប្អូនហ៎ា ឈ្មោះរបស់គាត់អាយុរបស់គាត់ប៉ុន្មាន
ឆ្នាំហើយ ហើយពួកគាត់ប្រកបមុខបបរអីគេដែរ?
ហើយជីវិតរបស់ពួកគាត់យ៉ាងម៉េចហើយ? ពូជួយ
រៀបរាប់ពីជីវិតរបស់ពួកគាត់មួយៗមក។
ខ៖ អាយុមើល...?
ក៖ កូនបងគេ?
ខ៖ កូនបងឈ្មោះ ពោធ កីមសាន្ត។
ក៖ ចា!
ខ៖ ខ្ញុំចាំតែឆ្នាំគាត់ទេណ៎ា ចាំតែឆ្នាំគាត់ៗកើតឆ្នាំ១៩០០
បែប៥៩ហើយយ៉ាង(១៩៥៩) តែ អត់ដឹងថ្ងៃខែឆ្នាំគាត់ទេ។
ក៖ គាត់កើតឆ្នាំ១៩៥៩គាត់អាយុដំណាលចាំខ្ញុំឥឡូវវាចូលដល់៥០...។
ខ៖ ៥៧ហ៎ា។
ក៖ ហ្នឹងហើយ។
ខ៖ពេលគាត់ស្លាប់ហ្នឹងអាយុ៥៧ឆ្នាំ។
ក៖ ចា! ចូល៦០ហើយក្បែរ៦០។
ខ៖ ប៉ាទ! ក្បែរ៦០ឆ្នាំហើយ។
ក៖ អញ្ចឹងគាត់ស្លាប់បាត់ហើយពូហ៎?
ខ៖ ប៉ាទ! ស្លាប់គាត់ស្លាប់ខែ០៧ហ្នឹងឆ្នាំ២០១៧ហ្នឹង។
ក៖ អញ្ចឹង? គាត់ស្លាប់ដោសារមូលហេតុអីដែរពូ?
ខ៖ ស្លាប់ហ្នឹងដូចវាអាការៈជម្ងឺគាត់ៗទៅឱ្យពេទ្យមើលអីវាជាអស់ហើយណ៎ា។
ក៖ ចា!
ខ៖ ជាអស់ហើយ ប៉ុន្តែគាត់ស្លាប់ដោសារពូលម្អូត។
ក៖ អឺម! គាត់ញ៉ាំតែម្អូតទទេតើអី? មិនមែនគាត់ញ៉ាំម្អូតជាមួយស្ករសរណាអី?

ខ៖ គាត់ញ៉ាំ...ថ្ងៃហ្នឹងគាត់ញ៉ាំច្រើនណាស់ គាត់ធ្វើនំបញ្ចកគាត់ធ្វើអាម៉ុក
គាត់ដឹកជាកាស គាត់ដឹកកាហ្វេហើយគាត់ញ៉ាំម្បូត តែប៉ុន្មានម៉ោងសោះ។
ក៖ តែប៉ុន្មានម៉ោងគាត់ស្លាប់តែម្តង?
ខ៖ ជ៉ាទ! អត់មានយកទៅដល់ពេទ្យទាន់ទេ។
ក៖ អញ្ចឹងគាត់ស្លាប់ដោយសារពុល?
ខ៖ ពុលៗម្បូតហ្នឹងហ្អង។
ក៖ ចុះពេទ្យគេ....? ហ្ន៎! អត់បានយកទៅពេទ្យឱ្យពេទ្យពិនិត្យទេ?
ខ៖ យកទៅក៏ប៉ុន្តែមនុស្សស្លាប់នៅនេះបាត់ហើយហ្នឹង
បានយកទៅពេទ្យៗថាស្លាប់បាត់ ហើយហ្នឹង។ គាត់យកបាយទៅឱ្យប្តីគាត់ហាស
គាត់ហូបបាយហើយអត់ទាន់បានផឹកទឹក ផងហ្នឹង
កូនគេប្រាប់ថាម៉ែស្លាប់បាត់ហើយ តែគាត់ជិះកង់ឱ្យភើយហ្នឹងហ៊ា ជិះកង់ដឹកចៅ
តែមិនដឹងយ៉ាងម៉េច។
ក៖ ពូអាការៈបែបហ្នឹងស្លាប់បែបហ្នឹងកម្រនឹងមានកើតឡើងណាស់។
ខ៖ ជ៉ាទ!
ក៖ ស្តាយណាស់ពូនេះ?
ខ៖ ជ៉ាទ!
ក៖ បើសិនគាត់ស្លាប់ដោយសារជម្ងឺអីចឹង។
ខ៖ អឺម! ក្មួយមកគោះទ្វារមកប្រាប់ខ្ញុំអត់ជឿមែន
ប៉ុន្តែខ្ញុំដូចជាសង្ស័យគាត់មកម្តងហ្នឹង ខ្ញុំ មានអារម្មណ៍ថាប្លែកហ៊ាគាត់ប្លែក។
ក៖ មកលេងផ្ទះពូហ្នឹងហ្អ?
ខ៖ ជ៉ាទ! មកលេងថ្ងៃ០៩ខែ០៧ហ្នឹងគាត់មកលេងទៅលេងផ្ទះក្មួយគាត់អឺ! ផ្ទះ
កូនគាត់នៅ ហួសព្រះវិហារយើងបន្តិចហ្នឹង។
ក៖ ជ៉ា!
ខ៖ ទៅហ្នឹងហើយស្រាប់តែដល់ថ្ងៃថ្ងៃហ្នឹងថ្ងៃទីប៉ុន្មានអញ្ចេះ? ថ្ងៃទី២៥ខែ០៧ហ្នឹង
ស្រាប់ តែម៉ោង១០ក្មួយមកគោះទ្វារប្រាប់ថាម៉ែស្លាប់
ស្លាប់ហើយដឹកគាត់ទៅបាត់ដំបងហ្អ៎ ដាក់ នៅពោធ៍ចិនតុងផ្ទះជួលហ្នឹង
ម៉េចគេឱ្យដាក់? ដល់ហើយទៅទាំងយប់ហ្នឹងជួលឡានគេ ទៅទាំងយប់។
ក៖ ជ៉ា!
ខ៖ ហើយពេលហ្នឹងខ្ញុំអត់មានលុយមួយរៀល
នៅក្នុងផ្ទះហ្នឹងហើយមិនដឹងគិតយ៉ាងម៉េច ទេ
ដល់ហើយក្មួយតេមកប្រាប់ថាឥឡូវក្មួយជួលឡានគេ ហើយឡានគេអស់ប្រ
មាណ៧០ដុល្លាបានទៅទាំងយប់ហ្នឹង ទៅដល់នោះម៉ោងប៉ុន្មាន?
ម៉ោង២ម៉ោង៣ភ្លឺដល់ ហើយជិតភ្លឺ ដែរបានទៅដល់
ហើយឥឡូវនៅបងស្រីខ្ញុំមួយទៀតនៅជាមួយបងថ្លៃ ខ្ញុំតាំងពីនេះមកមិន
ដែលបានទៅសួរសុខទុក្ខអីសោះ។
ក៖ ជ៉ា! អញ្ចឹងបងទីមួយគឺស្រីនោះ?
ខ៖ ជ៉ាទ!
ក៖ ហើយដល់ពេលទី២គាត់ឈ្មោះអីដែរ?
ខ៖ បងទី២ឈ្មោះ ពោធសារី ដែរ។
ក៖ ស្រីដែរមែន?
ខ៖ ស្រីដែរ។
ក៖ សព្វថ្ងៃគាត់រស់នៅណាដែរពូ?
ខ៖ គាត់នៅជាមួយបងថ្លៃខ្ញុំនៅពោធ៍ចិនតុងដែរហ្នឹង។
ក៖ អញ្ចឹងហ្អ? ហើយបន្ទាប់មកទៀត?
ខ៖ បន្ទាប់មកខ្ញុំកូនទី៣ហើយដល់ទីបួនឈ្មោះ ពោធ សុភក្រ័។
ក៖ ប្រុសហ្អ?
ខ៖ ស្រីដែរ ហើយគាត់កើតនៅឆ្នាំ៧៧(១៩៧៧)។
ក៖ គាត់ទើបតែអាយុ៣០ជាងក្បែរ៤០។
ខ៖ តែគាត់ស្លាប់នៅជំនាន់ប៉ុលពតបាត់ហើយ។
ក៖ អញ្ចឹង? គាត់ស្លាប់ដោយសារមូលហេតុអីដែរពូ?
ខ៖ គាត់ស្លាប់ដោយសារគាត់ឈឺហាស
កាលហ្នឹងគាត់ឈឺៗអត់មានថ្នាំមើលអីចឹងហ្អងហើ យ ប្អូនស្រីមួយទៀត ពោធ
សុភ័ក្រ ប្អូនទី៥ហ្នឹងហ៊ាក៏ស្លាប់នៅឆ្នាំ១៩៧៨ដែរ។ គាត់កើត

ប្រហែលបាន៣ខែដោយសារវាឈឺកាលហ្នឹងកាលជំនាន់ហ្នឹងអត់មានថ្នាំទេ។ ខ្ញុំ
នៅតូចខំ ព្យាយាមដើរទៅសូមដូងគេនៅកន្លែងសហករគេហ៎ា។
ក៖ ចា៎!
ខ៖ សូមកន្លែងទីពួកយោធាអីហ្នឹងហ៎ា ហើយខ្ញុំគេឱ្យដូង
ហើយតែឡើងអត់រួចឡើងបេះដូង អត់ រួចព្រោះដើមវាខ្ពស់ពេកអត់ហ៊ានឡើង។
ក៖ ដើមខ្ពស់ៗហើយត្រង់ទួ។
ខ៖ ហ្នឹងហើយ ត្រង់ទួអញ្ចឹងទៅ
ដើរមកសំគេដល់មើល....នៅខាងលិចស្វាយរៀងដើរទៅ ហ្នឹង
ដើរចង់មួយថ្ងៃវាស់ល្ងាចហ្អ៎ទៅដល់ស្វាយរៀងទៅសំគេៗឱ្យហើយនៅតែឡើងអត់
រួច ហ្នឹង ហើយប្អូនស្លាប់នៅព្រៃដំឡូងប្អូនទី៥ហ្នឹង
ប្អូនទី៤ហ្នឹងក៏ស្លាប់នៅបាត់ដំបង។
ក៖ សរុបទៅស្លាប់ប៉ុន្មាននាក់នៅរស់ប៉ុន្មាននាក់ពូ?
ខ៖ ប៉ាទ?
ក៖ ស្លាប់ប៉ុន្មាននាក់នៅរស់ប៉ុន្មាននាក់?
ខ៖ បងប្អូនហ៎?
ក៖ ចា៎!
ខ៖ បងប្អូនស្លាប់អស់ពានាក់ហើយ។
ក៖ នៅសល់២នាក់ហ៎?
ខ៖ នៅសល់២នាក់បងស្រី ពោជសារី។
ក ស្តាយណាស់ពូនេះ?
ខ៖ ប៉ាទ!
ក៖ បងប្អូន៥នាក់ ច្រើនហើយនៅមានពានាក់ទៅធុតឆ្ងាយទៀត។
ខ៖ ប៉ាទ!
ក៖
អញ្ចឹងពូចាំសាច់រឿងអីគេខ្លះទាក់ទងជាមួយនឹងបងប្អូនពូកាលពីនៅក្មេងៗ?
ខ៖ កាលពីនៅនេះហ្នឹងគាត់នៅក្នុងស្រុកភូមិ យើងវាអត់អីទេណា
ឆ្នាំប្រហែលជា៧៨ (១៩ ៧៨) ហ្នឹងចាប់ផ្តើមគេដំលៀសហ៎ា
ដំលៀសពីស្រុកកំណើតមកនៅស្រុកស្វាងនៅព្រៃវែង នៀក
នៅព្រៃវែងប្រហែលជាបានមួយឆ្នាំប្រហែលជា២ឆ្នាំចុះ បាន២ឆ្នាំគេបញ្ជូនទៅភ្នំពេ
ញវិញ។
ក៖ ម៉េចបានគេបញ្ជូនមកភ្នំពេញវិញ?
ខ៖ គេបញ្ជូនយើងទៅបាត់ដំបងហ៎ស។
ក៖ អូ!នៅក្នុងសម័យពលពតហ្នឹងហ្អ?
ខ៖ ប៉ាទ! នៅក្នុងសម័យប៉ុលពតហ្នឹង។
ក៖ ពូអាយុប្រហែលប៉ុន្មាននៅក្នុងសម័យហ្នឹង?
ខ៖ ក្នុងសម័យហ្នឹងខ្ញុំអាយុ៩ឆ្នាំទេប្រហែលជា១០ឆ្នាំហ្នឹង។
ក៖ ចា៎!
ខ៖ ដល់ពេលគេបញ្ជូនពីស្រុកមកៗនៅស្រុកស្វាងប្រហែលបាន២ឆ្នាំ គេចាប់ផ្តើម
ដំលៀស មកទៀតហ៎ាស មកអ្នកលឿងហ្នឹង។
ក៖ ចា៎!
ខ៖
មកអ្នកលឿងហ្នឹងអាគេបញ្ជូនអ្នកមុនទៅអស់ទៅក៏ជំនួសកន្លែងគេហ្នឹងហើយ។
គេ យកយើងទៅហ្នឹងទៅនៅអាកន្លែង គេអាកន្លែងដែរគេយកទៅបាត់ហ្នឹងហ៎ា។
ក៖ ចា៎!
ខ៖
មកដល់ហ្នឹងជិះកប៉ាល់ហើយដើររាប់ខែហ៎ាសបានទៅដល់អ្នកលឿងឡើងកប៉ាល់
ឡើងកប៉ាល់មកបានមកចុះនៅច្បារអំពៅនៀកចុះច្បារអំពៅហើយបានឡើងឡា
នទៅរ៉ាំរនេះភ្លើង។
ក៖ ចា៎!
ខ៖ ឡើងរ៉ាំរនេះភ្លើងហើយឡើងទៅហ៎ាជិះទៅខេត្តបាត់ដំបង។
ហើយទៅដល់ហ្នឹងខ្ញុំចាប់ ផ្តើមបែកបងប្អូនអស់ហើយ តែនៅជួបបងទី២បង
ពោជសារី ទៅដល់គេចាប់ផ្តើមគេឱ្យយើ

ងទៅនៅផ្ទះដែលគេធ្វើឱ្យហ្នឹងគឺផ្ទះដែលគេអាម្ចាស់គេហ្នឹង គេដំលៀសចេញ
អស់ហ្នឹង ណា។
កះ ចា!
ខះ ម្ចាស់គេដំលៀសចេញពីហ្នឹងគេលេងឱ្យនៅហ្នឹងគេទៅផ្សេងហ្នឹង
គេឱ្យពួកយើងអ្នកថ្មី ហ្នឹងទៅនៅ ដេកបានមួយយប់ទេៗខ្ញុំព្រលឹមឡើង
(ចុះនៅព្រៃវាអាប់ច្រើនណាស់ឃើញភ្នំឱ្យសន្លឹម)
ក៍នឹកក្នុងចិត្តថាបើគេឱ្យដើរទៅមិនដឹងជាប៉ុន្មានរយៈខែបានដល់ទេ? ស្រាប់តែ
ស្អែកឡើងគេឱ្យទៅមែន។ គេឱ្យកុមារទៅកន្លែងកងកុមារ
ឪពុកម្តាយគេទៅខាងកងឪពុក ម្តាយទៅ។
កះ គេបំបែកយើង។
ខះ គេបំបែកយើងហួង
គេឱ្យទៅចាំចាបទៅអីណាចុះនៅក្នុងកងកុមារគេឱ្យទៅចាំចាបអី
តាមវាលស្រែអីចឹងទៅណា។
កះ ចា!
ខះ ប្រហែលជាពីរយប់ដេកបានពីរយប់កន្លែងកងកុមារគេៗជូនទៅហួង។
កះ ប៉ុន្មាននាក់ទៅដែលគេបញ្ជូនទៅ?
ខះ គេបញ្ជូនទៅហ្នឹងកុមារជាង២០នាក់
ជាង២០នាក់ដើបទៅតាំងពីម៉ោង៤យប់។ ម៉ោង៤
យប់ដើរទៅហួងហូបបាយតាំងពីម៉ោង៤យប់ហ៎ាសៗ
ហើយដើរទៅរហូតទៅដល់កន្លែង ហ្នឹងម៉ោង៧យប់។
កះ ម៉ោង៧យប់?
ខះ ហ្នឹងហើយ ហូបបាយហើយធ្វើការទៀតធ្វើការទាល់តែម៉ោង៩យប់វិញទៀត។
ម៉ោង៩ ម៉ោង១០យប់ទៀត គេដឹកអាប្រឡាយៗ១២មេសាម៉ែច
គេនោះអាប្រឡាយហ្នឹង ប្រឡាយ គេសម្រាប់ដាក់ខ្មោចដាក់មនុស្សហ្នឹងហ៎ា។
កះ គេកប់ខ្មោច។
ខះ គេកប់ខ្មោច។ គេឱ្យជីកប្រឡាយហ្នឹង
ហើយឃើញគេធ្វើទារុណកម្មមនុស្សឃើញគេសម្លាប់។
កះ សម្លាប់ម៉ែចខ្លះទៅពូ?
ខះ ជួនកាលអ្នកធ្វើការជាពីសេសនារីៗដែលវាឃើញស្អាតអីហ្នឹង
គឺវាចាប់ផ្តើមរកលេសរក រឿងហ៎ាស។
កះ អឺម! ម៉ែចទៅជាអញ្ចឹងទៅ? វាចង់សម្លាប់ចោលម្ចងហ៎?
ខះ វាឃើញវាចង់ចាប់រំលោភចាប់អីចឹងទៅ
ដល់ឃើញដើរខុសអីតិចវាដើរចោទហ៎ាស។ វា
ចោទ...វាចាប់យកទៅហើយចាប់យកទៅសម្លាប់។
កះ អាក្រក់អាក្រីហ៎ាពួណេះ?
ខះ ប៉ាទ! វាសម្លាប់ហើយឧបមាផ្លូវយើងដើរអីចឹងហ៎ាស។
វាអត់កប់ទីណាឆ្ងាយពីផ្លូវទេ ប្រហែលជា៥ម៉ែត្រពីផ្លូវយើងហ្នឹង
ហើយវាកប់អត់ជ្រៅជិតទៀត។
កះ ងាប់ហើយ។
ខះ
នៅឃើញជើងឱ្យច្រង៉ាងទៅឱ្យសត្វហែកស៊ីពេញតែព្រៃហ្នឹងទៅស្អុយពេញតែព្រៃហ្នឹ
ងទៅ។
កះ គ្រាន់តែយើងដើរកាត់ហ្នឹងក៍ស្អុយដែរ។
ខះ
ស្អុយឃ្លាតតែពីខ្មមយើងនៅប្រហែលមួយរយម៉ែត។ហ្នឹងហើយៗសុទ្ធតែសត្វព្រៃហ្នឹង
។
កះ មនុស្សស្លាប់ច្រើនណាស់។
ខះ ខ្ញុំនឹកនៅក្នុងចិត្តថាខ្ញុំលេងបានទៅស្រុកវិញហើយ មិនដឹងជាពេលណា
បានទៅស្រុក វិញទេ
ដល់តែពេលវៀតណាមវាយចូលមកម្នករក្នុងភ្នំពេញគេចាប់ផ្តើមដំលៀសហ៎ា។
កះ ចា!
ខះ ដំលៀសទៅកន្លែងហ្នឹងដែរ ពួកកម្មករហ្នឹងទៅធ្វើការជាមួយពួកខ្ញុំដែរហ្នឹង
ដល់តែពេល គេដំលៀសពួកហ្នឹងទៅគេចាប់ផ្តើមដកពួកខ្ញុំចេញ

គេចាប់ផ្តើមរត់ចោលតែម្តង។ មុនដំបូង គេថាគេដកខាងចុះពីភ្នំទៅវិញហ្នឹងហ៎ា
។
កៈ ហ្នឹងហើយ។
ខៈ
ខ្ញុំដើរបីយប់បីថ្ងៃចេះតែដើរចុះដើរឡើងដើបឡើងគេរត់ទៅចោលអស់អាលីង។
កៈ សល់តែពូមួយនាក់ឯង?
ខៈ មេៗវារត់ចោលអស់ម្តង។
កៈ ហ្អ៎! សល់តែក្មេងៗនៅ?
ខៈ ហ្នឹងនៅសល់តែក្មេងៗមួយក្រុមពីរក្រុមដែលទៅជាមួយគ្នាហ្នឹងទៅ
ដល់គេខ្លះគេធំៗ គេដឹងៗទៅគេរត់ចោលយើងអស់ហើយ។
កៈ ហ្នឹងហើយ។
ខៈ ឥឡូវពួកយើងឃើញគេធ្វើអីយើងធ្វើហ្នឹងដែរទៅ
មានអីយើងឃើញគេធ្វើអីគេលែង មានពីណាគ្រប់គ្រងពីណា
ហើយរត់ចោលយើងពួកវាភ័យពួកវារត់ឡើងលើភ្នំអស់ហើយ។
វាៗបាននិយាយដែរវាថាអាណាអត់មានម៉ែឪអត់មានអីទៅតាមគេទៅគេចិញ្ចឹម។
អញ្ចឹងវាបម្រុងនឹងការយើងឡើងភ្នំហ៎ា។
កៈ ចា៎!
ខៈ ដំអញ្ចឹងទៅខ្ញុំក៏ទៅរកស្រូវកើបស្រូវកើបអីបុក ហើយបុកយើងមានក្បាលអី
រកភួយចេះ
តែរើសទៅភួយអ្នកណាភួយអ្នកណីក៏ដោយកាយដីកាយអន្លង់បុកទៅ។
ហ្នឹងហើយៗរើស ផ្តាំងដាំបាយដាំអីហូបទៅ
រហូតដល់តែជួបបងប្អូនជីដូនមួយពីរនាក់ទៀត កូនអ៊ុំខ្ញុំគាត់មក
ជួបគ្នាៗមានអ៊ុំៗនៅស្រុកភូមិជាមួយគ្នាហ៎ា ចេះតែទៅជាមួយគ្នាហើយ។
គេឱ្យរែកក៏រែក នឹងគេ គេឱ្យទៅក៏ទៅហ្នឹងគេទៅ ដល់តែពេលមួយទៀត។
វាជិតបែកមែនទែន ហើយណា
ពួកនេះហ្នឹងគាត់...ពួកមូលដ្ឋានគេដឹងអញ្ចឹងហ៎ាស។ គេដឹងថាយួនវាយចូលមក
អញ្ចេះ មួយៗ គេរកច្រកចេញទៅច្រកនេះច្រកនោះអញ្ចឹងទៅ
គេចេះនាំផ្លូវអញ្ចឹងទៅណា៎។
កៈ ចា៎!
ខៈ ទៅតាមគេទៅរិចអង្គរិចអីទៅតាមគេទៅ
ទៅគេស្នាក់តាមផ្លូវទៀតវិសតែហ្នឹងដាប់អា គេស្នាក់ហ្នឹងហ៎ស
ហើយដើរកាត់ខ្សែត្រៀមគេហ៎ា។
កៈ ហ្នឹងហើយ។
ខៈ កាត់ខ្សែត្រៀមគេដល់ហើយបាន២នាក់នោះគេចេះដោះសារទៅណា
ថាគេមកពីឫស្សី ក្រាំងអញ្ចេះមួយៗទៅ តែការពិតយើងរត់ចេញពីគេហ្នឹងហ៎ាស
បានរួចៗមួយក្រោទៀតទៅ រួចខ្លួនមួយក្រោទៀតហើយណា
រួចដាប់មួយវគ្គទៀតហើយ។
កៈ ព្រលឹងចុងសក់ណា៎ពូ។
ខៈ អាហ្នឹងដល់តែវគ្គក្រោយចូលមកដល់ខ្សែត្រៀមគេចាញ់សម្លាប់ចោលតែម្តង
ស្អុយ ពេញតែព្រៃហ្នឹង បាននៅសម្រាកហ្នឹងប្រហែលជាបួនប្រាំថ្ងៃ
ចាប់ផ្តើមចេញពីហ្នឹងចេញ មករកផ្លូវជាតិហ៎ាស
ចេញពីឫស្សីក្រាំងទៅក្រលោមផ្លូវកប៉ាំនៅខេត្តបាត់ដំបងហ្នឹង ចាប់
ផ្តើមចេញមកក្រៅ ដល់ហើយខ្ញុំបានមកដល់ផ្លូវជាតិ
ហើយមកដល់ផ្លូវជាតិឃើញគេដើរ ទៅទៅតាមគេហ្នឹង ចេះតែទៅតាមគេ
ផ្លូវហ្នឹងទៅស្រុកយើងហ៎ាស គិតថាផ្លូវហ្នឹងទៅស្រុក យើង ហើយក៏ចេះតែទៅៗ
យប់កន្លែងណាដេកកន្លែងហ្នឹងទៅ។
កៈ អត់មានទិសដៅទៅណាទេហើយមិនដឹងម៉ែឪនៅទីណាទេ។
ខៈ ហ្នឹងហើយ គឺដឹងតែថាផ្លូវហ្នឹងផ្លូវទៅស្រុកយើងហើយ ចេះតែទៅៗតាមគេទៅ
ដល់តែ ទៅៗអ្នកស្រុកភូមិជួបគ្នាអញ្ចឹងទៅថា អូ! ន៎ក
ម៉ែហែងនៅទីនេះម៉ែហែងនៅទីនោះអីចឹង ទៅណា៎។ គាត់នៅក្រោយហ្អ៎ដល់អញ្ចឹង
យើងដឹងថាគាត់នៅក្រោយយើងអញ្ចឹងយើងនៅ
ឈប់ចាំទីហ្នឹងហើយបានដល់គាត់ដើរមកជុំគ្នាអញ្ចឹងបានទៅទៀត។
កៈ បានជុំគ្នាអត់ពូ?

ខ៖ ជុំបានជុំ។
ក៖ បានជួប? បងប្អូនដែរ?
ខ៖ ប៉ាទ?
ក៖ ទាំងបងទាំងប្អូនដែរ?
ខ៖ ហ្នឹងហើយបងថ្លៃខ្ញុំប្រពន្ធគាត់ក្មួយម្តាយហើយនឹងបងស្រី
បងស្រីនៅជាមួយខ្ញុំទេ។
ក៖ ចា!
ខ៖ គាត់បានជុំគ្នាបាន៤នាក់ហើយ។
ក៖ ហ្នឹងហើយ។
ខ៖ ហើយហ្នឹងអ៊ុំ។
ក៖ ហើយម៉េចទៀតពូ?
ខ៖ បានជួបជុំងប្អូនហើយជួបជុំបងប្អូនបានហើយ។
ក៖ អូ! អារម្មណ៍ក្តុកក្តួលម៉េចទេពូណោះ? ពេលបានជួបគ្នាហ៎ាស។
ខ៖ បានជួបគ្នាហើយដល់តែពេលកាលហ្នឹងខ្ញុំវានៅតូចវាមិនទាន់ដឹងថា
គេសម្លាប់អីមិនសម្លាប់ទេណ៎ា
ក៏ប៉ុន្តែយើងអត់ដឹងគេភរថាសុទ្ធតែខ្មាំងអញ្ចេះមួយអញ្ចេះពីរអញ្ចឹងទៅ ណ៎ា
សុទ្ធតែខ្មាំងមិនដឹងថាខ្មាំងហ្នឹងយ៉ាងម៉េចទេ។
ក៖ មិនដឹងទេថាស្អីគេខ្មាំង។
ខ៖
ចុះបើដើរទៅឃើញខ្មោចហ្នឹងគេថាខ្មាំងសុទ្ធតែខ្មាំងហើយហ្នឹងខ្មាំងយួនអញ្ចេះមួ
យៗ មានអាដើរទៅមួយរោងហ្នឹងគេដាក់តម្រៀបគ្នាទៀត។
ក៖ ឃើញម្ចង? ស្រស់ៗម្ចង?
ខ ឃើញហ្អងស្រស់ៗហ្អងឃើញគេដាក់ដេកទល់គ្នាហ្នឹង ឱ្យក្រៀបមួយរោងបណ្តោយ
ប្រ ហែលជា៥០ម៉ែតអីហ្នឹងបួនប្រាំល្វែងហ្នឹង សុទ្ធតែមនុស្ស
ដល់ហើយខ្ញុំសួរបងៗខ្ញុំថាចុម! មានរឿងអីគេហ្នឹង?
ឯងអត់ដឹងតែហ៎ាសគេទើបតែសម្លាប់យប់មិញថ្មីៗហ្នឹង ហើយខ្ញុំគ្រាន់
តែឮអញ្ចឹងលែងហ៊ានចេញពីផ្ទះ
ហើយខ្ញុំលែងហ៊ានចេញពីកន្លែងហើយអាដិតបែកហើយ ហ្នឹង
(ដិតបែកសម័យប៉ុលពត) បានចេញមកដល់ផ្លូវជាតិមកហើយចេះតែដើរមក។
ជួបបង ប្អូនរហូតមកដល់ជួបបងថ្លៃខ្ញុំហ្នឹងកាត់នៅឃ្វាលក្របីហ៎ា
គាត់យកបានក្របីពីរមកយកបាន មួយនឹម
មកគាត់ដាក់ដីកអង្ករៗដីកអីចឹងទៅណ៎ា ហើយមានយាយមួយនោះ ឈ្មោះយាយ
អីទេរើយ គាត់ឈឺណាស់គាត់ដើរអត់រួចទេ
ដាក់អ្នកជម្ងឺមួយហ្នឹងលើខ្នងក្របីហ្នឹងទៀត។ ហើយដើរអឹម!រាកម្យ៉ាត់នោះលើស
ការកម្យ៉ាត់ទៀត។ ចេះតែដើរៗនិយាយរួម ដើរយប់នោះ
ចេះតែដើរដល់ណាដេកហ្នឹង។
ក៖ ហើយអត់ដែលមានអីរឹសត្វអីមករំខាន?
ខ៖ អត់ទេ។
ក៖ ពួកហ្នឹងឃើញយើងចាំលបសម្លាប់អីអត់ទេណោះ?
ខ៖ វាផ្លាប់មកជួបមួយម្តងមើល...កន្លែងហ្នឹងគេហៅចម្ការ
អំពៅហ្នឹងកន្លែងហ្នឹងគេហៅចម្ការ អំពៅ
កន្លែងហ្នឹងវាព្រៃវាអីនៅអែមនឹងផ្លូវជាតិហ្នឹងហ៎ាស។ ពួកវាមកស្ទាក់ៗចាញ់ឡាន
យួន។ ហ្នឹងជួបកន្លែងហ្នឹងរត់វាអត់មានចាញ់អីប្រជាជនទេ
វាគ្រាន់តែចាញ់បន្តគ្នាតិចទៅ ហើយវារត់ចូលព្រៃអស់ទៅ។
ក៖ ចា!
ខ៖ ដល់អញ្ចឹងទៅយើងចេះតែមកទៀតមក។
បើទៅដល់កន្លែងណាយើងអស់ស្បៀងអីចឹង
ទៅកន្លែងណាមានស្រូវមានអង្ករមានដំឡូងអីទៅចូលទៅភ្នំទៅគាស់ទៅកាយអីម
កតាមគេតាមឯងទៅ ហើយដល់ហើយមកដល់កំពង់ឆ្នាំនេះអស់ស្បៀងហើយ
ដាច់ស្បៀង។ ដាច់ ស្បៀងអ្នកស្រុកហ្នឹងគេឃើញក្របូយើងស្អាតហ៎ាស
ប្របូយើងធំៗគេសូមទិញ។
ក៖ មានអ្នកសូមទិញទៀត?

ខ៖ គេសូមទិញដល់សូមទិញព្រោះយើងខ្វះអង្ករហ៉ាស ក៏ដូរយកអង្ករគេ។
ដូរអង្ករប៉ុន្មានដូ ចជា៦គៅហេ៉ ៦គៅប៉ុន្មានទេ?
មួយប៉ាវជាងហើយបានធ្វើដំណើរទៅទៀតហើយ។ ហើ
យអាក្របីហ្នឹងយកចូលភ្នំពេញយការហូតមកដល់ស្រុកហ្អ៉។ មកដល់ហើយមកដល់
ជិត ចូលដល់ព្រែកភ្នៅនៀកវេទនាមែនទែន ហើយខ្ញុំវាដើរហាលថ្ងៃពេកទៅវា
ចូលដីវាចូល ភ្នែកហ៉ាស ដីចូលភ្នែកវាកើតភ្នែកក្រហមដើរមើលផ្លូវអត់យើញទេ
ហើយគេមកចោលខ្ញុំ អស់ហើយ។
គេទៅចោលដល់តែពេលបើកភ្នែកទៅគេទៅប្រហែលជា២០ ៣០ម៉ែត ហើយ
គ្មានកាន់អីកើតទេ។ វាឈឺភ្នែកហ៉ាស ហើយមានថ្នាំមានអីលេបណា កាលមកដល់
ហ្នឹង ទៅគេចែកគេយើញក្មេងៗអត់មានខោអាវអីចឹងទៅគេចែកខោអាវអីឱ្យ
ហ្នឹងមកចូលដល់ ជិតដល់ព្រែកភ្នៅហ៉ា ទេមកដល់? ហ្នឹងមកដល់ព្រែកផ្នៅហើយ
ត្រាន់តែដើរពីបាត់ដំបង មកដល់ស្រុក០៣ខែ។
ក៖ ងាប់!
ខ៖ ៣ខែបានទៅដល់ស្រុកកំណើតវិញ។
ក៖ ហើយម៉េចបានពូដឹងទិសដៅដើរមកដល់ភ្នំពេញ?
មការកពីណាគេវិញពេលហ្នឹង? ទិសដៅរបស់ពូហើយហ្នឹងគ្រួសារហ៉ា?
ខ៖ ការពិតនៅក្នុងគំនិតម្នាក់ៗដឹងតែទៅស្រុក
អីចឹងហ្មងទៅស្រុកកំណើតយើងហ្មង។ អា
ហ្នឹងជួបជុំក្រុមគ្រួសារហើយមកដល់នេះហ្នឹង។
ក៖ មកដល់ភ្នំពេញហេ៉?
ខ៖ ប៉ាទ! មកដល់ភ្នំពេញ។
ក៖ ម៉េចបានជួបជុំគ្នា?
ខ៖ មកជួបៗតាំងពីនៅជិតស្វាយរោងកែវហ្អ៉ ជួបជុំម្តាយខ្ញុំបងស្រីខ្ញុំបងថ្លៃខ្ញុំ
ហើយនិង បង ស្រីខ្ញុំមួយទៀត។
ក៖ ចុះពេលហ្នឹងឱពុករបស់ពូ?
ខ៖ ឱពុកខ្ញុំស្លាប់ហើយ។
ក៖ ស្លាប់នៅក្នុងប៉ុលពតមែន? ឬក៏ស្លាប់មុនប៉ុលពត?
ខ៖ ស្លាប់ក្នុងជំនាន់ប៉ុលពតហ្នឹងស្លាប់ក្នុងឆ្នាំ៧៩(១៩៧៩)ហ្នឹងហ្មង។
គាត់មានជម្ងឺហ៉ា។
ក៖ ច៉ា!
ខ៖ ដល់តែមានជម្ងឺហ្នឹងអត់មានថ្នាំព្យាបាលគាត់រួចអណ្តាតអត់មានថ្នាំអីលេប
ហើយវាខ្វះ អត់មានអីហូបផង។
ក៖ ឱពុកពូឈ្មោះអ្វីដែរ?
ខ៖ ឱពុកខ្ញុំឈ្មោះ ពោជសម្បត្តិ។
ក៖ ច៉ា! ពូចាំថ្ងៃខែឆ្នាំកំណើតគាត់ទេ?
ខ៖ អ៉! ឆ្នាំកំណើតខ្ញុំអត់ចាំខែទេ តែមានឆ្នាំនៀកគាត់កើតឆ្នាំ១៩៣៣។
ក៖ ហើយទីកន្លែងកំណើតាត់កើតនៅណាដែរពូ?
ខ៖ អ៉! កន្លែងកំណើតគាត់កើតនៅភូមិចុងរុក ឃុំរមាំងកោរ ស្រុករំដួល
ខេត្តស្វាយរៀងដែរ ដូចនឹងស្រុកជាមួយម្តាយដែរ។
ក៖ ច៉ា! កាលគាត់នៅរស់គាត់ប្រកបមុខរបររកស៊ីអីគេដែរពូ?
ខ៖ គាត់ជាកសិករៗ។
ក៖ ច៉ា! ធ្វើស្រែចម្ការហ្នឹងហ្នំ?
ខ៖ ប៉ាទ! ធ្វើស្រែចម្ការអីទៅ។
ក៖ ប្រសិនជាពូអាចរៀបរាប់ពីប្រភេទនឹងអត្តចរិតរបស់ឱពុកពូហ៉ាស
តើគាត់ជាមនុស្សប្រ ភេទយ៉ាងម៉េចដែរ?
ខ៖ អូ! គាត់មានទំនួលខុសត្រូវសម្រាប់គ្រួសារខ្លាំងណាស់។
សូម្បីតែគាត់កាលពីឆ្នាំ៧៥ (១៩៧៥) ដែលគេចូលក្នុងរបបប៉ុលពត
ហើយនិងក៏គ្រួសារអត់ពិបាកទេ ប្រហែលជាមួយ ឆ្នាំពីរឆ្នាំអត់ពិបាកទេ។
ក៖ ច៉ា!
ខ៖ គាត់រកស្រូវរកអីទុកដាក់អញ្ចឹងទៅ
ហើយដល់ពេលគេបែកគេបែងចែកហ៉ាស។ គេបែង ចែកសហការ
គេលែងឱ្យនៅភូមិយើងហើយផ្ទះកំណើតយើងក៏អត់ដែរ។ គេជំលៀសចេញ
នៅក្នុងស្រកអាដែលហ្នឹងហ៉ាស តែគេឱ្យចេញគេធ្វើផ្ទះ

ធ្វើផ្ទះរើផ្ទះគេថាផ្ទះគម្រូហ៊ាគេធ្វើ តាមប្រឡាយហ្នឹង
ហើយរស់នៅតាមផ្ទះគម្រូហ្នឹងមួយជួរៗតាមប្រឡាយអីចឹងទៅ និយាយរួមគេបំបែកយើងឱ្យនៅភូមិកៀរអាករយើងគេមិនឱ្យនៅទេ។
ហើយកាលហ្នឹងគាត់គេឱ្យគាត់នៅមើលថែទាំក្របីហ៊ា។
ក៖ ចា៎!
ខ៖ គាត់ជាប្រធានខាងមើលក្រប់ក្រងក្របីគោអីចឹងទៅ
ហើយជំនានហ្នឹងកន្លែងសហករ ហ្នឹង គេមានកន្លែងក្របីអីចឹង
យប់ឡើងគេចងមួយជុំគ្នាអីចឹងទៅ ហើយដល់តែលើក
ក្រោយមកគេឱ្យយកទៅចងតាមស្រែហ៊ា។
ក៖ ចា៎!
ខ៖ វាដូចថាឱ្យអាជីវកម្មក្របីដែលវាជុះហ្នឹងទៅជាជីនៅក្នុងស្រែហ្នឹង
ទៅហើយចល័តពី ភូមិមួយទៅភូមិមួយអីចឹងទៅណា
រហូតដល់ពេលមានវៀតណាមវាយចូលមកយើងក៏ចា
ប់ផ្តើមបែករត់ចេញមកវិញទៀត។
ក៖ រត់រហូត?
ខ៖ រត់រហូត ចុះបើយើងនៅជាប់ព្រំដែនហ៊ាស
ព្រំដែនហ្នឹងតិចទៅហើយផ្ទះយើងវានៅ លយចូល
ទៅគេហ្នឹងសុទ្ធតែជាតំបន់សមរភូមិហើយរត់មកដំលៀសៗមកនៅជិតខេត្ត។
ក៖ ចា៎!
ខ៖ ជិតខេត្តខ្លះដល់តែពេលឮស្រប់ស្ងាត់អីក៏ទៅវិញទៀតទៅ
ប៉ុន្តែទៅអត់បានយូរទេ ទៅ នៅអត់បានយូរទេ។
ត្រូវតៅរកភៀសខ្លួនចេញមកភៀសខ្លួនលើកចុងក្រោយហ្នឹង ភៀសមកលែងនៅស្រុកកំណើតកើតហើយមកនៅខាងព្រៃដំឡងមកនៅខាងស្រុកស្វាង។
ក៖ ចា៎!
ខ៖ រហូតដល់គេដំលៀសទៅដល់បាត់ដំបង ហើយម្តាយៗខ្ញុំសម្លាប់នៅ២០១២។
ក៖ អូ! អញ្ចឹងគាត់ស្លាប់គឺរួចផុតសម័យប៉ុលពតហើយហ្ន៎?
ខ៖ រួចហើយ។
ក៖ គាត់ស្លាប់ដោយសារអីដែរឬ?
ខ៖ គាត់លើសឈាមហើយគាត់កើតបូសគាត់កើតពិសហ៊ា។
ក៖ ចា៎!
ខ៖ គាត់ពិសអីចឹង ទៅគាត់មិនទៅពេទ្យទេគាត់ទៅឱ្យគ្រូខ្មែរផ្តុំ ដល់តែផ្តុំទៅវាៗជិតអាមុខ វាហ៊ាស។
កាលណាវាកើតបូសកាលវាជិតមុខវារុលចូលក្នុងវិញទៅណា។
ក៖ ហ្នឹងហើយ។
ខ៖ វាស៊ីខួងទៅក្នុងវិញហើយ
ដល់អញ្ចឹងទៅគាត់ឈឺពេកគាត់ឱ្យកូនដឹកទៅពេទ្យយក ទៅវះ
ហើយគាត់មានជម្ងឺទឹកនោមផ្អែមទៀត ដល់តែវះៗបានមួយយប់ៗគាត់ស្លាប់។
ក៖ កាលគាត់ស្លាប់គាត់មានអាយុប៉ុន្មានដែរឬ?
ខ៖ គាត់អាយុ៧៨ឆ្នាំ។
ក៖ ហ្ន៎! គាត់រាងចាស់ដែរហើយ។
ខ៖ ប៉ាទ! រាងចាស់ដែរហើយ៧៨។
ក៖ គាត់ឈ្មោះពេញឈ្មោះអ្វីដែរ?
ខ៖ ឈ្មោះទិត្យ ប៉ែន។
ក៖ ចា៎! ថ្ងៃខែឆ្នាំកំណើតគាត់ពូចាំទេ?
ខ៖ ស្គាល់តែឆ្នាំហ្នឹង ឆ្នាំកំណើតគាត់១៩៣៤។
ក៖ ទឹកន្លែងកំណើតរបស់គាត់?
ខ៖ នៅភូមិជុករុក ឃុំរមាំងកោរ ស្រុករំដួល ខេត្តស្វាយរៀងដែរ។
ក៖ ចា៎! កាលគាត់នៅរស់តើគាត់ប្រកបមុខរបរអីគេដែរឬ?
ខ៖ មើល...ចាប់ពីឆ្នាំ៨០(១៩៨០)ជាងមកគាត់ទៅលក់ៗនំម្អងចេកហ៊ាស។
ក៖ ចា៎!

ខ៖ គាត់លក់ដូរលក់នំអ្នងចេកលក់អាកោរលក់អីចឹងទៅ
ដល់ទៅពេលឆ្នាំ៨០(១៩៨០) ជាង
គាត់ឈប់ៗលក់ឈប់ដូរគាតទៅវត្តទៅរៀនធម៌ហ៊ា។
ក៖ ចា!
ខ៖ គាត់ទៅរៀនធម៌ជាមួយលោកគ្រូ បុតសារង្សូ។ គាត់ទៅមើល...នៅវត្តអីគេ?
នៅខាង វត្តឬស្សីសាញ់គាត់ទៅរៀនធម៌នៅហ្នឹង
ដល់ហើយគាត់ឈប់ពីរៀននៅហ្នឹង គាត់ទៅបាត់ ដំបងទៅរៀនជាមួយលោកគ្រូ
បុតសារង្សូនៅបាត់ដំបង។ នៅហើយនៅជាមួយនឹងបងស្រី
ខ្ញុំផងដោយសារបងថ្លៃខ្ញុំ
គាត់ទៅនៅហ្នឹងទៅធ្វើជាអ្នកលក់សំបុត្រយន្តហោះនៅនឹងព្រ
លានបាត់ដំបងហ្នឹងគាត់នៅហ្នឹងយូរហើយតើ។
ក៖ ចា!
ខ៖ ដល់ហើយគេខាងក្រុមហ៊ុនហ្នឹងគេចែកផ្ទះឱ្យមួយ
ចែកផ្ទះឱ្យមួយឱ្យបងខ្ញុំហ្នឹងហើយ គាត់ទៅនៅមើលចៅមើលអីចឹងទៅណា។
ក៖ ចា!
ខ៖ ដល់តែគាត់មកធ្វើការនេះ គាត់នៅហ្នឹងមើលផ្ទះមើលអីឱ្យគាត់ហ្នឹងទៅ ហើយ
រហូតដ ល់គាត់ទទួលមរណៈភាពនៅឆ្នាំ២០១២ហ្នឹងហៅនៅជាមួយចៅស្រី។
ក៖ ពូចាំសាច់រឿងអីគេខ្លះទាក់ទងពីម្តាយរបស់ពូ?
ជាមួយនឹងគាត់នូវអនុស្សាវរីយ៍ដែលពូ មានជាមួយហ្នឹងពួកគាត់ហ៊ា?
ខ៖ កាលគាត់នៅរស់ហ្នឹងខ្ញុំធ្វើការនៅរោងចក្រនេះហ៊ាស។
គាត់ទៅលក់នំអាកោរលក់នំ
អ្នងចេកហ្នឹងទៅពេលមកវិញមកអីហ្នឹងគាត់ទិញម្ហូបមក។
កាលហ្នឹងវាជីវភាពវាមិនមានទេ គ្រាន់តែថាបានហូបអញ្ចឹងហ៊ា។
ក៖ ចា!
ខ៖ ដោយសារម្តាយលក់ដូរតិចតួចអីចឹងទៅ
លក់អាកោរលក់នំអ្នងចេកអីចឹងទៅក៏មានម្ហូប មានអីហូបគួរសមដែរ។
ក៖ ចា!
ខ៖ ដល់តែពេលគាតរាងចាស់ទៅគាត់ថាឈប់លក់អាហ្នឹង
ហើយគាត់ទៅរៀនធម៌វិញ។ គាត់ថាគាត់ទៅរៀនធម៌ហើយ
ហើយទៅខ្ញុំសួរគាត់ថាម៉ែឯងទៅប៉ុន្មានខែមកវិញ? គាត់ថា មិនដឹងប៉ុន្មានខែទេ
ការពិតគាត់ទៅបួសនៅវត្តធ្វើដូនជីរហូតហ្នឹងណា ដល់អញ្ចឹងទៅគាត់
លែងបាននៅជុំជាមួយនឹងខ្ញុំហើយគាត់ទៅវត្តទៅរៀនធម៌វិញ។
ក៖ បែកពីពូហើយ?
ខ៖ បែក ដល់ហើយបងខ្ញុំមួយរយៈហ្នឹងគាត់ឈប់នៅណេះហ្នឹងហើយ
គាត់ចង់បានដីនៅ ស្រុកហ្អ៊ុ។
ក៖ ចា!
ខ៖ មានភូមិមួយអញ្ចឹងទៅហើយបានស្រែមួយហិចតាអីចឹងទៅ
គាត់ទៅចាប់ដីយក (ហ្នឹង គេចែកឱ្យទេមិនមែនចាប់ទេគេចែកឱ្យទេ)។
គេឱ្យគាត់ប្រហែលជាមួយហិចតាអីចឹងទៅ។
គាត់ទៅធ្វើស្រែរអញ្ចឹងៗទៅជួនកាលពេលគេច្រូតកាត់ហើយគាត់ឡើងមកភ្នំពេញ
ខ្លះទៅគាត់ទៅមកៗហ្នឹង ដល់ប្រហែលជាឆ្នាំប៉ុន្មានទេ?
គាត់យកបងស្រីខ្ញុំទៅនៅជាមួយដែរ។
ក៖ ចា!
ខ៖ ប្រហែលជាឆ្នាំ៨៩(១៩៨៩) ឆ្នាំ៩០(១៩៩០)ហ្នឹងដូចជា៨៩(១៩៨៩)
ដល់តែនៅចុះនៅ ឡើងគាត់លក់ស្រែហ្នឹងក៏លែងនៅទៅគាត់ទៅនៅបាត់ដំបង
គាត់រៀនជាមួយលោកតា បុត សារង្សូ។ គាត់ទៅរៀនធម៌ហ្នឹងរហូតទៅ
រហូតដល់គាត់ស្លាប់ពេលគាត់ស្លាប់ គាត់អត់បាន នៅជុំជាមួយខ្ញុំទេ។
ក៖ ចា! អត់បានជុំគ្នាទេណោះ?
ខ៖ ប៉ាទ!
ក៖ អញ្ចឹងពូនៅចាំសាច់រឿង
ឬឪពុកម្តាយពូប្រាប់ថាកាលពួកគាត់នៅក្មេងម៉េចដែរ? ពីជីវិត
ស្នេហារបស់ពួកគាត់កាលពីជួបគ្នាបែបម៉េចអីចឹងហ៊ា គាត់ដែរធ្លាប់ប្រាប់ពូទេ?

ខ៖ កាលហ្នឹងខ្ញុំនៅតូចៗគាត់ធ្លាប់និយាយប្រាប់ដែរ
ក៏ប៉ុន្តែខ្ញុំអត់សូវបានចាំដោយសារ
ឃើញថាពេលដែលឪពុកខ្ញុំមកដណ្តឹងម៉ែខ្ញុំហ្នឹងណាថាឪខ្ញុំតាខ្ញុំហ្នឹងគាត់ប្រាប់ខ្ញុំ
ថាឪគេកូនគេហ្នឹងជាអ្នកករកស៊ីក្តៃតែយកទៅ
ហ្នឹងហើយគេប៉ុនរកស៊ីអញ្ចឹងទៅណា។ កាលជំនាន់ហ្នឹង
គាត់ដឹកស្រូវដឹកអីយកទៅលក់នៅស្រុកយួនហ៎ាស?
ហ្នឹងហើយៗក៏បានជួបគ្នាអីចឹងទៅ។ កាលហ្នឹងខ្ញុំនៅតូចៗណាស់
រហូតដល់កាលហ្នឹងខ្ញុំនៅតូចៗណា ដល់ពេលអាជំនាន់ប៉ុលពត មួយសារទៀត
បែកបងប្អូនសូម្បីតែបងប្អូនជីដូនមួយនៅជិតគ្នាហ្នឹង ក៏អត់ឱ្យជួបគ្នា ដែរ។
បងប្អូនជីដូនមួយនៅប្រហែលមួយភូមិពីគ្នាក៏មិនហ៊ាននៅជួបគ្នាដែរ។
ក៖ ខ្លាចហ្ន៎?
ខ៖
គេអត់ឱ្យទៅជួបហ្អងគេឱ្យទៅទាល់តែយើងមានសំបុត្រស្នាមចេញពីប្រធានយើង
អីចឹង ទៅ។
ក៖ ត្រូវសូមច្បាប់សូមអីទៀត។
ខ៖ ត្រូវសូមច្បាប់សូមអីចឹងទៅ វាតឹងរឹងណាស់ជំនាន់ហ្នឹង
ហើយគ្រាន់តែប្រជាជនថ្មី និង ប្រជាជនចាស់
គេហ្នឹងអាប្រជាជន១៧មេសាហ្នឹងក៏គេអត់ឱ្យជួបគ្នាដែរ។ សូម្បីតែយើងបង
ប្អូនក្នាក់ដោយក៏គេមិនសូវរាប់អានយើងដែរ គឺគេប្រកាន់ចរិតអញ្ចឹងហ្អង។
ក៖ ចា៎! ហើយចុះពូចាំសាច់រឿងឬក៏ឈ្មោះរបស់តាយាយខាងឪពុកពូទេ? តាយាយ
ខាងឪពុកហ៎ា?
ខ៖ តាយាយខាងឪពុកខ្ញុំអត់សូវចាំទេ។
ក៖ ពូចាំអីគេខ្លះ?
ខ៖ បើខាងម្តាយចាំ។
ក៖ អញ្ចឹងពូជួយរៀបរាប់តាយាយខាងម្តាយតិចមើល? ឈ្មោះអីគេខ្លះ?
ខ៖ តាយាយខាងម្តាយឈ្មោះតាយិន។
ក៖ តាយិន! ចាំឈ្មោះពេញទេ?
ខ៖ ហ្នឹងហើយឈ្មោះគាត់អឺ!ឈ្មោះអីគេទេ...? ទិត្យ យិន ហើយយាយឈ្មោះយាយ
ភឿក
តែគាត់ស្លាប់អស់ហើយ។
ក៖ ចា៎! ចុះឪពុកម្តាយពូធ្លាប់ប្រាប់ទេថាយាយរបស់ពូកាចខ្លាំងអត់
ហើយគាត់ថែរក្សាបី ជាច់ពូទេកាលនៅពីតូច?
ខ៖ អូ! តាបើតា យិន គាត់កាចណាស់គាត់ចេះចាប់សសៃរ
តាគាត់ចេះចាប់សសៃរ គាត់ ចេះធ្វើចង្អេរធ្វើល្អីអីហ្នឹងៗ។ គាត់មានមាឌធំណាស់
គាត់មានមាឌធំហ្អងបើថាគាត់ទៅភូមិ ណាគឺផ្អើលភូមិហ្នឹងតែម្តង។
ក៖ មាឌគាត់ដាំងពេក។
ខ៖ ហ្នឹងហើយ។
ក៖ ចេញមកមានអំណាចហ្អង?
ខ៖ ចេញមកគាត់គ្រាន់តែសើចហ្នឹងឆ្លងឮភូមិមែនហ្នឹង។ កាលពីសម័យប៉ុល ពត
គាត់នៅ រស់ហ្នឹងហើយខ្ញុំកើតទាន់គាត់ដែរ តែយាយៗគាត់ពេលបែក៧៥
(១៩៧៥) ហ្នឹង។ គាត់ ស្លាប់ហើយតែខ្ញុំនៅចាំពេលគេយកធាតុគាត់ហ្នឹង
ខ្ញុំជាអ្នកកាន់ធាតុគាត់យកទៅបញ្ចុះនៅ ទួលកប់ខ្មោចហ្នឹងគេហៅទួលព្រីចហ្នឹង។
ក៖ ចា៎!
ខ៖ ប៉ាទ! ហើយដល់តែយាយខាងឪពុកអត់សូវចាំ។ យាយខាងឪពុកយាយដូចជា
ឈ្មោះ យាយ ញឹម តែបើតាអត់ចាំឈ្មោះគាៗ។
ក៖ អញ្ចឹងតាយាយខាងឪពុកគឺអត់ចាំទេ?
ខ៖ ប៉ាទ!
ក៖ អញ្ចឹងទាក់ទងជាមួយនឹងសាច់ញាតិរបស់ពូហ៎ា?
តើពួកគាត់រស់នៅប្រទេសកម្ពុជាទាំង អស់ ឬក៏មានពីណានៅក្រៅប្រទេស?
ខ៖ ប្រហែលជានៅក្នុងប្រទេសកម្ពុជាទាំងអស់ហ្នឹង
អត់មានពីណានៅក្រៅប្រទេសទេ។
ក៖ ចា៎! ហើយទាក់ទងជាមួយនឹងជីវិតអាពាហ៍ពិពាហ៍របស់ពូវិញហ៎ា
តើភរិយារបស់ពូ ឈ្មោះអ្វីដែរ?

ខ៖ គាត់ឈ្មោះ រស់ គម។
ក៖ ចា៎! ហើយពូរៀបអាពាហ៍ពិពាហ៍ហ្នឹងរយៈពេលប៉ុន្មានឆ្នាំហើយ?
ខ៖ កាលពីឆ្នាំ១៩៨៦។
ក៖ ចាំថ្ងៃខែទេពូ?
ខ៖ ថ្ងៃខែអត់ចាំទេ។
ក ប្រហែលជារដូវវស្សា រដូវគក្តិ ចែត អីចឹងហ៎ា?
ខ៖ ប្រហែលជាខែចែត្រហើយ។
ក៖ ខែចែត្រប្រហែលជាខែបីខែបួនហើយ?
ខ៖ ហ្នឹងខែបីខែបួន។
ក៖ រដូវក្តៅនេះ?
ខ៖ ចា៎ទ!
ក៖ ហើយអាពាហ៍ពិពាហ៍របស់ពូហ្នឹងត្រូវបានផ្តួរផ្គងដោយឪពុកម្តាយ ឬក៏ពូចង់និយាយថា ជួបនឹងស្រឡាញ់អ្នកមីងដោយខ្លួនឯង?
ខ៖ ហ្នឹងហើយ ស្រឡាញ់ដោយខ្លួនឯងស្រឡាញ់ពេលធ្វើការរោងចក្រហ្នឹង ជាមួយគ្នាហើយម្តាយអ៊ុំគាត់មករៀបឱ្យដែរ។
ក៖ អញ្ចឹងហ៎? តាមប្រពៃណីអីចឹងទៅ?
ខ៖ ចា៎ទ!
ក៖ មានជាថ្លៃបណ្តាការឬក៏ថ្លៃទឹកដោះទេពូជំនាន់ហ្នឹង?
ខ៖ អត់មានទេ។
ក៖ ព្រោះពេលហ្នឹងវាជុតសង្គ្រាមហើយៗក៏មិនទាន់បបូរអីដែរ។
ខ៖ វាអត់អត់ទាន់បបូរទេ។
ក៖ ចា៎!
ខ៖
ដោយសារអ៊ុស្រីហ្នឹងគាត់ជាអ្នកលក់ដូរអញ្ចឹងគាត់រាងមានលុយច្រើនគិចទៅណា។
ក៖ ចា៎!
ខ៖ ហើយដូចជាពួកខ្ញុំៗមាន តែប្រាក់ខែអត់សូវមានលុយអី សម្រាប់ផ្គត់ផ្គង់ដូចថាមួយខែ សម្រាប់តែមួយខែហ្នឹងអត់គ្រប់ទៀតហ្នឹងហ៎ា។
ក៖ ចាស! អញ្ចឹងអើ!ពូមានកូនទាំងអស់ប៉ុន្មាននាក់ដែរ?
ខ៖ ៧នាក់ហ្ន៎។
ក ឈ្មោះអ្វីគេខ្លះទាំងពីបងរហូតដល់ប្អូនហ៎ា?
ខ៖ មីបងឈ្មោះ ពោជចិន្តា។
ក៖ ចា៎!
ខ៖ ហើយអាកូនទី២ឈ្មោះ ពោជ រដ្ឋា ប្រុស ហើយកូនទី៣ ពោជ រិមានប្រុសដែរ។
ក៖ ចា៎!
ខ៖ ដល់តែទី៤ ពោជ នាងប្រាក់ ស្រីហើយទី៥ ពោជ ស្រីមាស ស្រីដែរ។
ក៖ ចា៎!
ខ៖ ទី៦ ពោជ ប្រុសពេជ្យ ប្រុស ហើយនិង ទី៧ ពោជប្រុសនិល។
ក៖
កូនរបស់ពូទាំងអស់មានពីណាគេរៀបអាពាហ៍ពិពាហ៍ហើយរីនៅរីក៍នៅលើរទាំងអស់?
ខ៖ រៀបបានពីរហើយ។
ក៖ រៀបបានពីរហើយ។
ខ៖ ពោជ រិមាន ហើយហ្នឹង ពោជស្រីមាស។
ក៖
សព្វថ្ងៃពួកគាត់រស់នៅជុំជាមួយពូទាំងអស់រីក៍ពួកគាត់រស់នៅកន្លែងណាផ្សេង?
ខ៖ ពោជ រិមាន គេការហើយគេទៅនៅខាងប្រពន្ធគេ។
ក៖ នៅណាវិញពូ?
ខ៖ នៅព្រែកហូតឡរហ្នឹងគេទៅធ្វើការនៅបុរីហាយទិចនៅច្បារអំពៅ។
ក៖ ហើយក្រៅពីហ្នឹងនៅជាមួយហ្នឹងពូទាំងអស់?
ខ៖ នៅទាំងអស់។
ក៖ ចា៎! អញ្ចឹងក៏ដូចគ្នាផងដែរ ខ្ញុំចង់ដឹងពីចំនេះដឹងទូទៅរបស់ពូដែរអីចឹងហ្នឹងហ៎ា។ ពូ មានចេះភាសារអីផ្សេងក្រៅពីភាសារខ្មែរទេ?

ខ៖ អត់ចេះផងចេះតែភាសារខ្មែរទេ។
ក៖ ចេះអានចេះសសេរទេ?
ខ៖ ចេះអានចេះសសេរ។
ក៖ ហើយពូរៀនបានកម្រិតថ្នាក់ទីប៉ុន្មានដែរ?
ខ៖ ថ្នាក់ទី៨។
ក៖ ថ្នាក់ទី៨ជំនាន់មុនមែន? ឬក៏ទី៨ឥឡូវ?
ខ៖ ទី៨ឥឡូវហ្នឹង។
ក៖ ឥឡូវហ្នឹង។
ខ៖ ជំនាន់ឆ្នាំប៉ុន្មាន...? ឆ្នាំ៨៤(១៩៨៤)ហ្នឹង។
ក៖ ពូចាំឈ្មោះសាលាហើយហ្នឹងទីតាំងសាលានៅទីណាទេ?
ខ៖ មុនខ្ញុំរៀនអក្ខរកម្មនៅក្នុងរោងចក្រនៀក។
ក៖ ចា៎!
ខ៖ ដោយសារកាលហ្នឹងរដ្ឋគេឱ្យមានសិទ្ធិនៅតាមអង្គភាពគេៗបើកអក្ខរកម្មហ៎ា។
ក៖ ចា៎!
ខ៖ ដល់អាហ្នឹងយើងឆ្លងផុតពីគ្រោះ មិនចេះអ
ក្សរហើយបានគេបើកសាលាបំពេញវិជ្ជា ក្រៅម៉ោងនៅចាក់អង្រែហ៎ា។
ក៖ ចា៎!
ខ៖ យើងចូលរៀនចាប់ពីម៉ោង៥រហូតដល់ម៉ោង៨។
ក៖ ម៉ោង៥ព្រឹកហ្អ?
ខ៖ ៥ល្ងាចហ្នឹងយើងចេញពីធ្វើការហ្នឹង។
ក៖ ចា៎!
ខ៖ ចេញពីធ្វើការហើយយើងជិះកង់ទៅរៀនទៅ នៅសាលាចាក់អង្រែ
គេហៅបំពេញវិជ្ជា ក្រៅម៉ោងហ្នឹង។
ក៖ ចា៎!
ខ៖ ប្រឡងបាន...យើងប្រឡងបានផុតទៅយើងទៅរៀនថ្នាក់ទី៤ ជាប់ថ្នាក់ទី៤
អញ្ចឹងរៀន តទៀតដល់ឡើងថ្នាក់ទី៧ទី៨ទៅ ដល់ពេលនៅជំនាន់ហ្នឹងមានរឺដែអូ
ហើយហ្នឹងវាកូនបុក ចូលខ្លាំងមែនទែន ហើយខ្ញុំទៅរៀននៅសាលាគុយជា។
ក៖ ចា៎! នៅច្បារអំពៅ?
ខ៖ ប៉ាទ! ហួសច្បារអំពៅទៀតហ្នឹង ទៅតាមផ្លូវដាកទៅណាក៏គេបញ្ចាំងរឺដែអូៗ
ដល់ឃុរៗ ទៅលែងបានទៅរៀន។
ក៖ អាដែងតែទៅមើលរឿងមែន?
ខ៖ ហ្នឹងហើយអាដែងតែមើលរឿង។
ក៖ អឺម! ចាប់បណ្តោយអាដែងតែមើលរឿងទេអីចឹង។
ខ៖ ប៉ាទ! តែមូលហេតុហ្នឹង ដល់តែឃុរៗទៅអាពួកម៉ាកខ្ញុំថាគោះទៅរៀនវិញទៅៗ
ដល់តែ ឃុរទៅការងាររាចេះតែបន្តាន់ទៅៗក៏លែងបានរៀនទៅ។
ក៖ ក៏ឈប់ត្រឹមថ្នាក់ទី៨ហ្នឹងទៅ?
ខ៖ ក៏ឈប់ត្រឹមថ្នាក់ទី៨ហ្នឹងទៅ? ខ្ញុំស្តាយៗណាស់មិនបានបញ្ចាក់សញ្ញាបត្រទុក។
ក៖ អឺម! ចា៎!
ខ៖ ចេះតែហឹៗទៅ។
ក៖ ហឺអើៗ?
ខ៖
ហឺអើៗអញ្ចឹងទៅបើគេៗប្រឡងជាប់គេបញ្ចាក់សញ្ញាបត្រហើយឯងភ្លេចឱ្យឈឺង
យក មកហើយតែយកទៅឱ្យក្រូវិញ។
ក៖ ចា៎! អញ្ចឹងពូកាលសម័យពូនៅរៀនហ៎ា តើពូនៅចាំរឿងរ៉ាវសាច់រឿង និង
អនុស្សាវរីយ៍អីគេខ្លះជាមួយនឹងមិត្តភក្តិរបស់ពូហ៎ាកាលនៅរៀន?
ខ៖ កាលហ្នឹងមិត្តភក្តិយើងមានច្រើនណាស់មិត្តភក្តិខាងធ្វើការទេ។
ក៖ ចា៎!
ខ៖ ព្រោះវានៅធ្វើការរោងចក្រហ្នឹងយើងទៅរៀនទៅ យើងស្គាល់មិត្តភក្តិ
អ្នកដែលធ្វើការ រោងចក្ររៀនជាមួយគ្នា
តំប៉ុន្តែរោងចក្រកន្លែងដែលគេធ្វើផ្សេងៗគ្នាអីចឹងទៅណ៎ា។
ក៖ ចា៎!
ខ៖ ហើយពេលខ្លះទៅៗរៀនអឺ! ទៅរៀនអញ្ចឹងទៅកង់ខូចៗអញ្ចឹងទៅ
ជួនកាលយើងទៅ រៀនអត់ទាន់គេអញ្ចឹងត្រូវដើរពីរោងចក្រហ្នឹងទៅសាលាទៀត។

កះ ចា៎!
ខះ ហើយខ្ញុំគេជ្រើសរើសឱ្យធ្វើជាប្រធានផ្នាក់ ដោយសារគេមានវេនយប់
គេត្រូវការអ្នក កាន់អំបូលគេត្រូវការអ្នកថែទាំអាហ្នឹងហ៎ា។
កះ ចា៎!
ខះ នៅមើលថែទាំអំបូលហ្នឹង ដល់តែដល់ម៉ោងយើងត្រូវទៅឱ្យបានមុនគេដើម្បី
រៀបចំអំពូ លអីចឹងហ៎ា។
កះ ចា៎!
ខះ ហើយមានមិត្តភក្តិល្អៗច្រើនណាស់នៅកន្លែងធ្វើការ
ដូចថាសុទ្ធតែមនុស្សធ្លាប់ឆ្លងកាត់ ការងាររាងៗខ្លួនហ៎ា។
កះ ចា៎!
ខះ ហ្នឹងហើយ ខ្លះទៅឥឡូវបែកគ្នាអស់ហើយឥឡូវលែងស្គាល់គ្នាអស់ហើយ។
កះ លេងចាំគ្នាអស់ហើយ?
ខះ ហ្នឹងវាបែកគ្នាយូពេកទៅ។
កះ អត់ដែលធ្លាប់ប្រទះជួបមិត្តភក្តិចាស់ៗអីឬចាំតិចតួចអីអត់ទេណោះ?
ខះ ជួប២នាក់ម្នាក់ទៀតនៅច្រកផ្សារក្រមួនហ្អ៎ ឈ្មោះគាត់ឈ្មោះ គីម វណ្ណៈ
គាត់មានមាឌ ធំមាឌដំបងៗ។
កះ ចា៎!
ខះ ហើយមួយទៀតគាត់ឈ្មោះ ឡញ។ កាលមុនផ្ទះគាត់នៅជិតអឹមហ្នឹងហ៎ា
តែដល់តែ គាត់លក់ហ៎ា។
កះ ចា៎!
ខះ អញ្ចឹងទៅនៅក្រោយហ្អ៎។
កះ បានសល់មិត្តភក្តិពីរបីចាំខ្លះដែរ។
ខះ នៅចាំមុខពីរបីក៏ប៉ុន្តែឥឡូវគាត់សក់ស្កូវអស់ហើយ
ហើយពេលជួបសួរគ្នាថាបានចៅ ប៉ុន្មាននាក់ហើយ? ខ្ញុំថា
(ខ្ញុំបានចៅ២នាក់ហើយ) ហើយគាត់សក់ក្បាលឡើងសសំពោងៗ។
កះ ហ្នឹងហើយ! ហើយពូទាក់ទងជាមួយនឹងបទពិសោធន៍ការងារ
តាំងពីតូចដល់ធំធ្លាប់ធ្វើ ការអីគេខ្លះដែរ?
ខះ និយាយពីធ្វើការខ្ញុំគ្រាន់តែធ្វើការជាមួយរោងចក្រមោងនៀក។
កះ ជាការងារដំបូងហ៎?
ខះ ដំបូងហើយហ្នឹង១២ឆ្នាំធ្វើនៅហ្នឹង។
កះ ធ្វើតាំងពីនៅតូច។
ខះ ហ្នឹងហើយនៅតាំងពីធ្វើការមិនកើតហ៎ា ហើយកាលហ្នឹងដូចថាចុះឈ្មោះចេះតែ
ធ្វើទៅ ព្រោះការងារដូចវាមិនជាប់លាប់ប៉ុន្មានហ៎ា។
កះ ចា៎!
ខះ វាជួនកាលមានជួនកាលអត់អីចឹងទៅ។
កះ ហើយបន្ទាប់មកទៀតពូបានធ្វើការអីទៀត?
ខះ ចប់ពីធ្វើការហ្នឹងហើយ ខ្ញុំទៅធ្វើការនៅកំពង់ស្ពឺ
(បន្ទាប់ពីធ្វើការ១២ឆ្នាំនៅហ្នឹងហើយ) មើលទៅនេះ
ក៏ទៅកំពង់ស្ពឺទៅធ្វើការជាមួយបងទៅ ធ្វើព្រូឡានបងរណ្ណាហ្នឹង ទៅសល់
នោះហើយវាពិបាកជាងហ្នឹងទៅទៀត។ វាពិបាកប្រាក់ខែតិច
ហើយដល់ពេលប្រពន្ធកូន នៅទីនេះវាពិបាក។
កះ ទៅចោលឆ្ងាយ។
ខះ ទៅឆ្ងាយទៀត។
កះ ត្រឡប់មកវិញទៅ?
ខះ អត់ត្រឡប់មកវិញទេ នៅធ្វើការហ្នឹងបានយក។
បែកគ្នាកាលហ្នឹងទើបតែមានកូន២នាក់ទេៗបានយកទៅនៅកំពង់ស្ពឺជាមួយគ្នា
ទៅនៅកំពង់ស្ពឺបានប៉ុន្មានឆ្នាំ ទៅលក់ដូរ
ហើយទៅនៅជាមួយផ្ទះអ៊ុំហើយគ្នាវាច្រើន ដូចថាកូនហើយនិង គាត់វាមានទំនាស់
ទាស់ គ្នាហ៎ា។
កះ ចា៎!
ខះ ដល់ហើយទៅសម្រេចចិត្តមកនៅផ្ទះនេះវិញហ៎ា
ផ្ទះនេះបោះបង់ចោលម្តងហើយតើ។
កះ អញ្ចឹង?

ខ៖ ហ្នឹងហើយ។
ក៖ អឹម! អត់មានពីណាគេយកបោះចោលអីចឹងហើយ?
ខ៖ គេយកហើយហ្នឹង។
ក៖ អញ្ចឹង?
ខ៖ គេយកហើយហ្នឹង តែដោយសារមានបងមួយនោះឈ្មោះបងខា។
គាត់ប្រាប់ថាទៅ រឿទៅផ្ទះរឿទៅ ប្រយ័ត្នពួកគេណោះ គេបាក់សោរយកហ៎ា។
គេបាក់សោរយកតើ យើង អត់ទៅនៅរឿ ដល់អញ្ចឹងទៅខ្ចីមកពីកំពង់ស្ពឺមុន
មកពីកំពង់ស្ពឺទៅបាត់ដំបង ទៅបាត់ដំ បងជំនាន់អ៊ុនតាត់ចូលមកហ្នឹងហ៎ា។
ក៖ ចា៎!
ខ៖ ទៅធ្វើការជាមួយអ៊ុនតាក់ អ៊ុនតាក់ក៏ប៉ុន្តែមិនមែនទៅធ្វើការអីទេ
គឺទៅជួយលាងយន្ត ហោះគេសម្អាតយន្តហោះគេកាលហ្នឹង។
ក៖ ចា៎!
ខ៖ កាលហ្នឹងក៏វាសប្បាយដែរធ្វើការជាមួយពួកនេះ វាបានលុយច្រើនហ៎ា។
ក៖ ចា៎!
ខ៖ គេមិនឱ្យលុយទេ គេឱ្យជាប្រេង។
ក៖ ដូរឱ្យជាប្រេង។
ខ៖ ហ្នឹងហើយ គេដូរឱ្យជាប្រេងវិញ។
គេឱ្យលាងយន្តហោះមួយគេឱ្យប្រេងពីរធុងធំៗទៅ។
យើងចែកគ្នាទៅក៏ប៉ុន្តែពេលវេលាវាតិចណាស់ បានមួយនេះចុងក្រោយ
អត់អីធ្វើទៀត។ អត់អីធ្វើចូលទាហ៊ានទៀតហ៎ា។
ក៖ ចូលទាហ៊ានទៀត?
ខ៖ បាទ! ចូលធ្វើជាតម្រួតតនៅបាត់ដំបងបានតែប៉ុន្មាន
ខែគិតសព្វៗទៅប្រាក់ខែ តែកាល ហ្នឹងប៉ុន្មាន? ពីរម៉ឺនហ៎? ហ្នឹងហើយ
ប្រាក់ខែ២៨,០០០៛ គិតមើលមិនដឹងជាស៊ីអីទេ ដល់
អញ្ចឹងទៅឮដំណឹងថារោងចក្រគេបើក ហើយដូចរោងចក្រអឺមវេអីហ្នឹង។
ខ្ចុំឮដំណឹងគិត ទៅរកធ្វើការរោងចក្ររឿ
ឈប់ពីធ្វើតម្រួតហ្នឹងមករត់ចោលជួរទៀតហើយ។
ក៖ រត់ចោលជួរ?
ខ៖ រត់ចោលជួរ ហើយប្រពន្ធខ្ចុំហ្នឹងគាត់ទៅៗលេង
ស្រាប់តែគេស្គាក់បាញ់ឡានគាត់ហ្នឹង។ កាលខ្ចុំនៅតម្រួតហ៎ា
ស្រាប់តែគេទូរស័ព្ទមកថានៅជិតកៀកស្វាយដូនកែវ។
ក៖ ក្នុងឆ្នាំប៉ុន្មានពូ?
ខ៖ ឆ្នាំ១៩៩៤ហ្នឹង (កំពង់តែប្រទះសារ៉ាយហ្នឹង)។
ក៖ ហ្នឹងឆ្នាំ១៩៩៣មានបញ្ហា។
ខ៖ ហ្នឹង៩៣(១៩៩៣) ៩៤(១៩៩៤)ហ្នឹង ស្រាប់តែគេតែមក
ស្រាប់តែគេឱ្យពួកខ្ចុំហ្នឹង ឡើងឡានទៅៗអន្តរាគមន៍
ទៅដល់ហ្នឹងទាល់តែចូលផ្ទះបងខ្ចុំបានខ្ចុំដឹងដំណឹង បាន
ឮថាអញ្ចឹងប្រហែលប្រពន្ធហែងគេគៀងហើយ អញ្ចឹងបានដឹងថាគេគៀងទៅ។
គេយកទាំង ឡានហ៎ា អាឡានដឹកអីហ្នឹងវាប្លន់ហ្នងហ៎ា។
ក៖ យកអីយើងហ្នង។
ខ៖ ប្លន់យកលុយតែមានតែកូន(រិមាន)ហ្នឹងនៅកម្ពស់នេះហ្នឹង។
ក៖ ចា៎!
ខ៖ នៅកម្ពស់នេះស្លៀកខោក្រហមទៅ។
ក៖ គេគៀងទៅដល់ណា?
ខ៖ គេគៀងចូលទៅ អាហ្នឹងគេប្លន់តែបាន
គេជួយឱបក្នេងហ្នឹងលោតចេញពីឡានទៅណា
គេឱបមនុស្សប្រុសគេឱបលោតទៅប្រមៀលខ្លួនកុំឱ្យវាសង្កាត់ក្នេង ហើយក៏លោ
តចេញពី ឡានរួចទៅ ហើយអាឡានហ្នឹងក៏ចេះតែទៅៗ
(ប្រពន្ធក៏រមៀលខ្លួនទៅតាមក្រោយដែរ ខ្ចុំ វេទនខ្លាំងណាស់ជួបតែរឿងអញ្ចឹងៗ)។
ក៖ មីងវេទនាតែបើនិយាយថាពីជីវិតក៏សំណាងម្ល៉ាងដែរ គឺរួចផុតរហូតហ៎ា។
ខ៖ ការពិតគាត់ហ្នឹងគេឱ្យគាត់ទៅជួបព្រះហើយតាំងពីខ្មែរក្រហមដេញចាញ់ម្ល៉ះ។

កះ អាប៉ុលពតនោះមួយសារហើយ ថាផុតប៉ុលពត
នោះទៅបានរួចតែមកដល់ណេញទៀត ហើយថា!
ពូទាក់ទងពីខ្លួនពូផ្តាល់ពូមានជំនាញអីផ្សេងទេ? ដូចថាពូតែអីមួយអីចឹងហ៎ា?
ខះ ខ្ញុំសព្វថ្ងៃហ្នឹងដូចជាជំនាញជាមួយហ្នឹងពុម្ពអារហ្នឹង គ្រាន់តែឃើញគេ...
ឃើញគេហ្នឹង គិតថាអុញ អាហ្នឹងគេធ្វើអញ្ចឹងទេអី?
គ្រាន់តែឈរមើលគេធ្វើអីចឹងទៅចេះធ្វើតាមគេដែរ
ដល់អញ្ចឹងទៅគេឱ្យខ្ញុំឡើងធ្វើជាប្រធានក្រុម។
កះ ចា!
ខះ ឱ្យធ្វើពុម្ពធ្វើជាប្រធានក្រុមធ្វើពុម្ពហើយណា ហើយអាកាត់តាឡកគេសុទ្ធតែ
អក្សរចិន ទេ តែខ្ញុំអត់មានចេះចិនអីមួយម៉ាត់។
ខ្ញុំគ្រាន់តែឱ្យដឹងថាមួយណាប្រវែងខ្លួនមួយណា ទំហំ
ខ្លួនមួយណាជើងអារអាណាក្លៀកអាណាកអារ? គឺខ្ញុំធ្វើបានហើយ។
កះ ចា!
ខះ ហើយអក្សរចិនវាយ៉ាងម៉េចៗទៅ។
កះ អត់យល់ទេតែធ្វើបាន។
ខះ ហ្នឹងហើយ ហើយគេចេះចិនៗគេមកមើលហ៎ា
ពេលគេមកមើលគេថាគេអត់ចេះ ធ្វើគេ
អត់ចេះវាស់ម៉ែកហ្នងនិយាយរួមទៅគេអត់ចេះវាស់ម៉ែក។
កះ ដល់ពេលពូធ្វើបាន?
ខះ ធ្វើបាន។
កះ អញ្ចឹងពូមានជំនាញអីផ្សេងទៀតទេដែរពូពូតែធ្វើ?
ខះ ពូតែមានតែចេះជួសជុលកង់អីតិចតួចទៅ។
កះ ចេះធ្វើផ្ទះចេះធ្វើឧបករណ៍ភ្លេងអីអត់ពូ?
ខះ អត់ចេះទេ ហ្នឹងហើយកាលនៅពីតូចធ្លាប់ធ្វើទ្រមួយដែរ។
កះ ធ្លាប់ធ្វើទ្រ?
ខះ ធ្លាប់ធ្វើទ្រ។
កះ ពូចំណង់ចំណូលចិត្ត ពូចូលចិត្តធ្វើអីដែរ? ដូចថាជាកីឡាសិល្បៈតន្ត្រីអីចឹងហ៎ា?
ខះ ខាងសិល្បៈអីដូចអត់សូវចំណូលប៉ុន្មានទេ។
កះ ចេះកីឡាខ្លះៗដែរ?
ខះ ហ្នឹងហើយ កីឡាអីគ្រាន់ចង់លេងខ្លះដែរ។
កះ ចា! ហ្នឹងហើយពូនិយាយទៅពូរៀបរាប់ពីបទពិសោធន៍ជីវិតពូជូរចត់ខ្លាំង។
ខះ ប៉ាទ!
កះ ហ្នឹងការឆ្លងកាត់អីៗទាំងអស់អញ្ចឹង
ប្រសិនបើពូក្រឡេកមកមើលបទពិសោធន៍ដែល ល្បីៗវិញហ៎ា
ដូចជាមួយនឹងអាពាហ៍ពិពាហ៍? ទាក់ទងជាមួយនឹងកូនចៅឬក៏អីក៏ដោយ
ដែលពូគិតថាជាបទពិសោធន៍ល្អដែលធ្លាប់ឆ្លងកាត់នៅក្នុងជីវិតរបស់ពូហ៎ា
មានអីគេខ្លះ ដែរ?
កះ អាបទពិសោធន៍អាហ្នឹងទី១
គឺអាពាហ៍ពិពាហ៍ដែលយើងបានបង្កើតកូនចៅមកមើលថែ ទាំ
វាទោះបីខ្លះស្តាប់តាមបង្គាប់ខ្លះអត់ស្តាប់អីចឹងទៅ។
វាមានដែលថាគ្រប់រសជាតិអីចឹងទៅណ៎ា។
កះ ចា! ហើយពូដូចថាបានមកស្គាល់ពីសាសនាដែរ។
ខះ ប៉ាទ! រហូតបានមកស្គាល់ដំណឹងល្អនេះទៅ។
ការពិតទៅការស្គាល់ដំណឹងល្អនេះទី១គឺកូនប្រុស ពោជ វិមាន
គាត់បានចូលទៅមុនហ្នឹងណ៎ា។
កះ ចា!
ខះ ចូលទៅមុនយូរដែរ ប្រហែលជា៤ឆ្នាំយ៉ាងម៉េចទេ? ប្រហែលជា៤ឆ្នាំហើយ
គាត់ឃើញ ទៅឱ្យតែថ្ងៃអាទិត្យទៅបាត់ៗ (គាត់ថាទៅព្រះវិហារៗ)
តែមិនដឹងទៅធ្វើអីទេណ៎ា។
កះ ចា!
ខះ ស្រាប់តែថ្ងៃមួយនោះគាត់ៗធ្វើបុណ្យជ្រមុជទឹកហើយ
គាត់យកសៀវភៅគោលលទ្ធ និង សេចក្តីសញ្ញាមកគាត់កាន់យកចូលផ្ទះ
ហើយខ្ញុំឃើញខ្ញុំសួរថាចុះសៀវភៅអីធំម្ល៉េះ?សៀវភៅធំអីចឹងមើលប៉ុន្មានឆ្នាំបានច

ប់ទៅ? ហើយខ្ញុំអានចំណងជើងក៏អានអត់ដាច់ដែរ ការពិតសៀវភៅគោលិទ្ធ និង
សេចក្តីសញ្ញាហ្នឹងហ៎ តែអានមិនដាច់ទេ ដល់ហើយខ្ញុំឃើញ
សៀវភៅហ្នឹងសសេរពីច្បាប់សុខភាពហ្អ៎។
កៈ ចា៎!
ខៈ ខ្ញុំចាប់អារម្មណ៍ថាអឺម!សាសនាហ្នឹងល្អណ៎ា
គេហាមមិនឱ្យផឹកតែផឹកកាហ្វេផឹកស្រា ក្រឿងញៀនគ្រប់បែបយ៉ាងហ្នឹងល្អហ៎ា
ពីព្រោះខ្ញុំពីមុនហ្នឹងចូលសាសនាចក្រហ្នឹង ខ្ញុំក៏ចេះ ផឹកស្រាដែរ តែស្រាណាស់
តែគេបង្ខំខ្ញុំទេ តែបើឱ្យខ្ញុំទៅរកផឹកខ្លួនឯងខ្ញុំមិនដែលទេ ដល់អ
ញ្ចឹងទៅប្រហែលជាបីខែក្រោយមកទៀត រិ មាន បាននាំអ៊ែលឌើមកនាំអ៊ែលឌើ
មកពីរនាក់ មកអង្គុយចាំ ហើយគាត់សួរតែកាលហ្នឹងខ្ញុំអត់មានពេលមែន
ព្រោះខ្ញុំធ្វើការពីម៉ោង៧ ព្រឹកអីចឹង ទៅចូលមកវិញ។ ម៉ោង
១ហើយថែមម៉ោងដល់ម៉ោង៩យប់ហ្អ៎។ ដល់ ម៉ោង៩
យប់អត់មានពេលសោះដល់អីចឹងទៅ អ៊ែលលឌើ២នាក់គាត់មកៗ
គាត់សួរថាពរនាក់ហ្នឹង លោកពូរើសឱ្យអ្នកណាអធិស្ឋាន
(ខ្ញុំមិនដឹងអធិស្ឋានហ្នឹងយ៉ាងម៉េចគេទេ) ដល់ហើយខ្ញុំ
ជ្រើសរើសយកវិមានអធិស្ឋានៗអីចឹង
ហើយទៅបានអ៊ែលឌើគាត់ណែនាំអញ្ចេះមួយៗពី សាសនាចក្រហ្នឹងហ៎ា។
តើលោកពូមានពេលវេលាម៉ោងណា គាត់ចង់ដឹងពី ពេលវេលាហ៎ា
ពេលហ្នឹងដំអញ្ចឹងទៅខ្ញុំថាខ្ញុំអត់ទាន់មានពេលវេលាទេ
ដោយសារខ្ញុំជាប់ធ្វើការពីម៉ោង៧ ព្រឹក រហូតដល់ម៉ោង៩យប់ហ្អ៎បានចូលផ្ទះ។
កៈ ចា៎!
ខៈ ហើយពេលខ្លះហ៎ា សូម្បីតែមុខកូនលែងចង់បានជួបមុខ
អាខ្លះៗវាដេកយឺតម៉ោងអីចឹង អត់បានជួបមុខវាទេ។ យើងទៅធ្វើការជាត់ហើយ
និយាយពីរល់នោះរល់ពេក ប្រហែលជា បាន ៣ខែមកបានអ៊ែលលឌើមក
មកដល់ផ្ទះមកលេងហ្នឹងហ៎ា គ្រាន់តែមកលេងចុះឡើងៗ
ហើយគាត់មកលេងប្រហែលជាបានបីបួនដងៗ
បានថ្ងៃក្រោយបានឃើញបងសាយ័ន្តមក ដែរ។
កៈ ចា៎! ហ្នឹងហើយខ្ញុំចាំតើ។
ខៈ ហ្នឹងហើយ! ហើយខ្ញុំឃើញគាត់មកខ្ញុំថាអូ! កូនគេចេះច្រើនណាស់ៗ ដល់ហើយ
កាល ហ្នឹងកូនប្រាក់អីគេអត់ចង់ចូលទេ
បានហើយខ្ញុំនិយាយប្រាប់គាត់ថាមើលកូនគេៗនៅក្មេង ប៉ុណ្ណឹង
គេចេះច្រើនណាស់។ គេរៀនបានច្រើនណាស់ គេចេះអង់គ្លេសអីចឹងទៅបានហើ
យកាលហ្នឹងហ៎ា កុំអីត្រួសារបានចូលទាំងអស់ ហើយព្រោះអត់ដឹងថាក្រុមត្រួសារ
ត្រូវចូល ទាំងអស់គ្នាទេ
ហើយខ្ញុំក៏អត់ដឹងថាអ្នកណាខ្លះហើយអញ្ចឹងទៅអាខ្លះវាអត់ចង់អីទៅ តែបើ
កាលមុនកុំអីចូលទាំងអស់គ្នាហើយណាដំយើងអត់ដឹងអាអីចឹងក៏របូតអស់ពីរនា
ក់ៗ។
កៈ ចា៎!
ខៈ អស់ពីរៗនាក់ប្រពន្ធខ្ញុំហើយហ្នឹងកូនខ្ញុំកុំអីត្រូវចូលទាំងអស់គ្នាហ្នឹង។
កៈ តែគាត់អាចូលមកតាមក្រោយទៀតបានតើ។
ខៈ ប៉ាទ?
កៈ គាត់អាចចូលមកតាមក្រោយទៀតបានតើ។
ខៈ ហ្នឹងហើយ អាហ្នឹងវាត្រូវប្រើពេលយូរបន្តិចហើយពីរពេលនេះទៅហ្អ៎។
កៈ ហ្នឹងហើយ។
ខៈ អាហ្នឹងគាត់ត្រូវរងចាំអព្ភូតហេតុ ហើយបានគាត់ចូល
ហើយដល់ពេលបានរៀនជាមួយ នឹងអ៊ែលឌើរ
ហើយគាត់ប្រាប់ថាលោកពូមិនបាច់ជឿខ្ញុំទេ ឱ្យអធិស្ឋានសួរព្រះទៅ។ ពេល
ខ្ញុំលុតជង្គង់អធិស្ឋានទៅ។ ចុម! ស្រាប់តែយប់ហ្នឹងស្ងាត់ឈឹងអញ្ចឹង?
តែការពិតព្រះពន្យ
ល់ប្រាប់ប្រពន្ធខ្ញុំវិញហ្អ៎ប្រាប់រៀបរាប់ថាសាសនាហ្នឹងពិតអីចឹងទៅណ៎ា។
កៈ ចា៎!
ខៈ អញ្ចេះមួយអញ្ចេះពីរអីអញ្ចឹងទៅ
ហើយដល់ពេលថ្ងៃក្រោយមកឃើញប្រធានប៊ុនឡាយក៏គាត់ធ្លាប់មកដែរ

ហើយនិង ប្រធានសំអាតគីមស្រួយ ឪពុកគាត់ហើយនិង អ៊ុន សុផល
ហើយហ្នឹងភរិយាគាត់អញ្ចឹងទៅ ហើយឃើញបងសវ៉ាងអញ្ចឹងបានគិតថា អូ!
មិនមែននៅ តែឯងណា ដល់ហើយទៅអ៊ែល
ឱរគាត់សួរថាលោកពូទៅព្រះវិហារអត់? ទៅព្រះវិហារអត់ សប្តាហ៍ហ្នឹង?
ដល់អញ្ចឹងទៅខ្ញុំប្រាប់ថាខ្ញុំទៅៗ ដល់តែពេលខ្ញុំទៅដល់ព្រះវិហារ ហើយ
គាត់ប្រាប់ថាលោកពូទៅមួយម៉ោងក៏បានដែរ ទៅផ្ទះវិញក៏បានដែរ។ ខ្ញុំថាទេ
ខ្ញុំមករៀន បើ ខ្ញុំមកវិញមុនម៉ោងខ្ញុំម៉េចចេះ?
គេរៀនចោលខ្ញុំអស់ហើយបានខ្ញុំទៅព្រះវិហារ ទាល់រហូតអីចឹងទៅ។
កៈ រហូតមកដល់សព្វថ្ងៃទៅ?
ខៈ ជ៉ាទ! រហូតដល់សព្វថ្ងៃ ប៉ុន្តែមានការល្បងលបច្រើនណាស់
ពេលខ្ញុំចូលដំបូងហ៊ា។ មើលខ្ញុំចូលទៅព្រះវិហារ ខ្ញុំចូលបានបីសប្តាហ៍ហ្នឹងហ៊ា
ស្រាប់តែខ្ញុំមកវិញជិះបានត្រឹម រង្វង់មូលតាខ្មៅយើងហ្នឹងហ៊ា
ស្រាប់តែខ្ញុំចុកពោះរកមូលហេតុមិនឃើញចុកពោះ ចង់បក
មកក្រោយមិនកើតទៅមុខមិនកើតស្រាប់
តែនឹកឃើញអធិដ្ឋានទៅរកព្រះពីរនាក់ និល សួរ គាត់
ទៅដឹងហើយវាសួរជ៉ាមានរឿងអីហ្នឹងខ្ញុំថាចុកពោះហ៊ា ចុកពោះ ថាចុកពោះ
ជិះកង់ ហ្នឹង ទម្រាំមកដល់ផ្ទះបោះកង់ចោលចូលបន្ទប់ទឹក បានមកដល់ផ្ទះហ្នឹង
ល្បងលថាតើ យើងហ្នឹងមានសេចក្តីជំនឿទៅលើព្រះអត់?
ហើយដល់លើកក្រោយមួយដងទៀតៗ គេ ល្បងកាលហ្នឹងអត់ទាន់ជ្រមុជទឹកទេ
គេល្បងអារឿងផឹកស្រាហ៊ា។
កៈ ជ៉ា!
ខៈ ផ្ទះណា? ផ្ទះនេះហ្នឹងគេទិញមក ថ្ងៃហ្នឹងខំគេច អូ!
ជិះកង់ទៅដល់ម៉ូឌែនហើយហ្នឹងហ៊ា ប្រហែល១ម៉ោងជាង២ម៉ោង
ហើយគេមិនទាន់ចប់ទៀត។ គេចេញពីកន្លែងនេះទៅកន្លែង នោះហ្នឹង
នៅទល់មុខគ្នា។ អូ! គេស្រវឹងស្រែកឡូឡា ខ្ញុំផឹកតែ១កំប៉ុងសោះ ស្រាប់តែ៣ថ្ងៃ
ក្រោយមកចុកពោះ។ហ្នឹងបានហើយសួរមើល...អាពេជ្យ អានិល រិមាន ប្រាក់
លុតជង្គង់អធិ ស្ងានទៅព្រះទាល់តែអធិស្ងានទៅរកព្រះបានបាត់ហ្អង។
កៈ ហ្នឹងហើយ បានកូនចៅគាត់បានអំពាវនាវរអធិស្ងានទៅរកព្រះឱ្យជួយ។
អញ្ចឹងដូចថាពូ មានកូនមានចៅនៅពេលធំៗទៀត
ហើយទាក់ទងជាមួយនឹងបទពិសោធន៍ពូដែលបាន
រៀបរាប់ក្នុងការសម្ភាសនេះពួកគាត់នឹងបានស្តាប់ឮនៅពេលក្រោយទៀត។
អញ្ចឹងពូមាន
ជាពាក្យពេចន៍ឬក៏អ្វីដែលចង់ផ្តាំផ្ញើរជាដំបូន្មានទៅកាន់ពួកគាត់ហ៊ាពូ?
ខៈ នៅក្នុងសាសនាចក្រហ្នឹងវាល្អណាស់
ព្រោះយើងចូលទៅយើងបានរៀនបានសូត្រ បានស្គាល់ដំណឹងល្អ
អ្វីដែលវាដឹកនាំក្នុងជីវិតយើងឱ្យទៅល្អ ហើយសង្ឃឹមថាពេលកូន
ពេលចៅអីនៅពេលក្រោយចង់ឱ្យគាត់ដើរតាមគម្រូរនេះឱ្យល្អ។
ខ្ញុំចង់ឱ្យក្រួសារខ្ញុំទាំង អស់បានចូលទៅក្នុងព្រះវិហារ។
កៈ ជ៉ា!
ខៈ មិនដឹងថាគាត់នៅរង់ចាំអីទេសព្វថ្ងៃនេះ។
កៈ អត់អីទេតាមរយៈគម្រូរបស់ពូ ហើយនិងអ្វីដែលជាបទពិសោធន៍ និង
អ្វីដែលយើងធ្លាប់
ឆ្លងកាត់គាត់នឹងឃើញថាគាត់ចង់ឱ្យជីវិតរបស់គាត់ផ្លាស់ប្តូរពីភាពដែលលំបាក
ហ៊ា សម្រាប់ អនាគតរបស់ពួកគាត់នៅពេលទៅមុខទៀត។
ខៈ ជ៉ាទ!
កៈ អញ្ចឹងពូមានពាក្យអីបន្ថែមទេពីមុនការបញ្ចប់នេះ?
ខៈ គ្រាន់តែចង់ឱ្យក្រុមក្រួសារទាំងអស់
ឱ្យគាត់ទៅរកព្រះបែរទៅរកព្រះទាំងអស់គ្នា ទៅ ដើម្បីឱ្យយើងមានសេចក្តីជំនឿ
តែមួយដើម្បីកុំឱ្យវារែចុះឡើងអីចឹងហ៊ា។
កៈ ជ៉ា!
ខៈ ចំពោះសាសនាចក្រនេះជាសាសនាចក្រពិតដែរ
ដឹកនាំជីវិតយើងឱ្យបានភ្លឺថ្លា។
កៈ ជ៉ា!

ខ៖ ហើយមានគម្រូ ជាច្រើនដែរ គេបានជោគជ័យនៅក្នុងជីវិតរបស់គេ ពេលខ្លះយើងក៏ ជួបរឿងលំបាក
ពេលខ្លះយើងក៏ជួបរឿងមិនស្រួលសំខាន់យើងដើរតាមរហូតទៅ។
ក៖ ចា៎!
ខ៖ ពីព្រោះបើខ្ញុំគេចពីព្រះអារក្ស វានឹងអូសពួកយើងទៅ
ហើយពួកវានៅរងចាំយើងជានិច្ច ហ្នឹង។
គឺអារក្សវាធ្វើកិច្ចការរារហូតឱ្យតែយើងផ្លាត់តែបន្តិច គឺវាអូសយើងទៅហើយ គឺថាមានតែផ្លូវព្រះមួយទេ ដែលយើងបានសង្គ្រោះ ដូចជាយើងបានទៅថ្វាយបង្គំព្រះថ្ងៃសិល ជាថ្ងៃរបស់ទ្រង់ នឹងធ្វើឱ្យជីវិតរបស់យើង។
វាស្គាល់បុណ្យស្គាល់បាបអីចឹងហ៎ា ដឹងថា យើងដើរតាមផ្លូវព្រះ
យើងវាមានជួបហ្នឹងរឿងល្អច្រើន ដូចជា... ហើយសព្វថ្ងៃនេះ បើដើរ
ខុសពីផ្លូវព្រះហើយមានទៅណា?
មានតែធីកស្រាធីកអីធីកគ្រឿងញៀនសព្វបែបយ៉ាង វា
សព្វបែបយ៉ាងហើយសព្វថ្ងៃនេះ។
ក៖ ចា៎!
ខ៖ ហើយខ្ញុំបារម្ភ បំផុត គឺកូនៗភ័យខ្លាចតែគាត់ដើរទៅផ្លូវហ្នឹងទេ។
មើល...ល្ងាចឡើង គាត់ទៅព្រះវិហារគឺខ្ញុំសប្បាយចិត្តណាស់។
ក៖ គ្រាន់បើជាងទៅកន្លែងផ្សេង?
ខ៖ ចាទ! បើទៅកន្លែងផ្សេងសុទ្ធតែទឹកភ្នែកហើយ។
ក៖ ចា៎! អញ្ចឹងអរគុណពូច្រើនមែនទែនសម្រាប់ពេលវេលារបស់ពូ ដែលបានផ្តល់ពេល វេលាឱ្យខ្ញុំមកចុះជួបហើយដើម្បីបានស្តាប់ពីបទពិសោធន៍របស់ពូ៕